# ចូរប្រាកដចិត្តអំពីព្រះ

ហើយមានដំណើរដូច្នេះថា៖

*គ្រានោះ អេលីយ៉ា ជាអ្នកស្រុកធេសប៊ី…ជាម្នាក់ ដែលរស់នៅជាមួយនឹងអ្នកស្រុកកាឡាត បានទូលទៅកាន់ស្តេចអ័ហាប់ថា ទូលបង្គំស្បថដោយនូវព្រះនាម នៃព្រះជាម្ចាស់នៃ សាសន៍អ៊ីស្រាអែលដ៏មានព្រះជន្មរស់ដែលទូលបង្គំឈរនៅចំពោះទ្រង់នេះថា ក្នុងរយៈពេលបីឆ្នាំខាងមុខទីនោះនឹងគ្មានភ្លៀងហើយគ្មានសូម្បីតែសន្សើមទៀតផងលើកលែងតែដោយសារពាក្យទូលបង្គំប៉ុណ្ណោះ។*

*រួចព្រះបន្ទូលដែលចេញ ពីព្រះជាម្ចាស់កំពុងបង្គាប់មកកាន់លោកថា ចូរ ចេញពីទីនេះហើយ ត្រលប់ទៅទិសខាងកើតហើយលាក់ខ្លួន របស់ឯងក្បែរជ្រោះកេរិត—កេរី* (ខ្ញុំមានន័យថា) *វានៅទល់មុខនឹងទន្លេយ័រដាន់។ ហើយឯងនឹងផឹកទឹកពីជ្រោះហើយអញនឹងបញ្ជាក្អែក ចិញ្ចឹមឯង…*

*ដូច្នេះលោកក៏បានធ្វើតាមពាក្យរបស់ព្រះជាម្ចាស់ដែលមានបន្ទូលទៅលោកហើយលោកក៏បានទៅស្នាក់នៅក្បែរបឹងកេរីតដែលនៅមុខទន្លេយ័រដាន់នោះ។ ហើយរាល់ព្រឹករាល់ល្ងាចក្អែកបានយកនំប៉ុងនឹងសាច់មកឲ្យលោកហើយលោកនឹងផឹកទឹកពីជ្រោះនោះដែរ។*

*លុះ កន្លងយូរមកទឹកជ្រោះបានរីងស្ងួតព្រោះទីនោះគ្មានភ្លៀង សោះ។ នោះ ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានមានបន្ទូលទៅកាន់លោកថា*

*ចូរក្រោកឡើង ហើយធ្វើដំណើរទៅស្រុកសារិផាត ដែលជាស្រុករបស់ក្រុងស៊ីដូនហើយរស់នៅទីនោះអញនឹងបង្គាប់ឲ្យស្ត្រីម៉េម៉ាយម្នាក់នៅទីនោះមើលថែឯង។*

*ដូច្នោះ លោកបានសម្រេចចិត្តធ្វើដំណើរទៅស្រុកសារិផាត។ ពេលលោកបានធ្វើដំណើរដល់មាត់ទ្វាទីក្រុងហើយលោកបានឃើញស្ត្រី*

*ម៉េម៉ាយកំពុងប្រមូលកំណាត់ឈើនៅទីនោះហើយគាត់បានស្រែកហៅនាងថាសូមអ្នកអាណិតខ្ញុំសុំទឹកក្នុងផ្តិលអ្នកផឹកបន្តិចមក។*

*ពេលដែលនាងកំពុងតែទៅចាក់ទឹកឲ្យលោកនោះលោកក៏បានហៅនាងថាសូមយកនំបុ័ងបន្តិចឲ្យខ្ញុំហូបផង។ហើយនាងបានឆ្លើយថា ដោយសារតែព្រះនៃអ្នក ជាព្រះដ៏រស់ ខ្ញុំគ្មាននំបុ័ងទេតែមានតែ ម្សៅមួយ ក្តាប់នៅក្នុងខាប់ ហើយមានប្រេង បន្តិចបន្តួចនៅក្នុងដបប៉ុណ្ណោះ ហើយ អ្នកមើលឃើញខ្ញុំកំពុងប្រមូលកំណាត់ឈើពីរនេះ សម្រាប់យកទៅចំអិនសំរាប់ខ្លួនខ្ញុំ នឹងកូនប្រុសរបស់ខ្ញុំហូបតែប៉ុណ្ណោះហើយបន្ទាប់មកនឹងស្លាប់ទៅ។*

*តែបន្ទាប់មក អេលីយ៉ា បាននិយាយទៅកាន់នាងថា កុំខ្លាចអី សូមទៅធ្វើអ្វីដែលអ្នកបាននិយាយចុះ ប៉ុន្តែសូមធ្វើនំយ៉ាងតូចខ្ញុំហូបសិន ហើយបន្ទាប់មកធ្វើសម្រាប់អ្នកហើយ...កូនប្រុសរបស់អ្នកចុះ។*

*ដ្បិត ព្រះជាម្ចាស់នៃសាសន៍អ៊ីស្រាអែល (Israel) ទ្រង់មានបន្ទូលថា ម៉្សៅក្នុង ខាប់នឹងមិនចេះអស់ ហើយប្រេងក្នុងដបក៏មិនរីងឡើយ រហូតដល់ថ្ងៃដែលព្រះជាម្ចាស់បង្អុរភ្លៀងមកលើផែនដីវិញ។*

*ដូច្នេះ នាងបានទៅហើយធ្វើតាមពាក្យរបស់អេលីយ៉ា ហើយនាង និងលោក ហើយនឹងកូនរបស់នាងហូបបានជាច្រើនថ្ងៃ។ ហើយ ម៉្សៅនៅ ក្នុងខាប់ក៏មិនចេះអស់ប្រេងនៅក្នុងដបក៏មិនចេះរីងឡើយ ដូចជាព្រះបន្ទូលនៃព្រះជាម្ចាស់ដែលមានបន្ទូលតាមលោកអាលីយ៉ា។*

សំរាប់នៅព្រឹកនេះមុននឹងខ្ញុំធ្វើដំណើរទៅប្រទេសក្រៅ ខ្ញុំបាន យក អត្ថបទ៖ *ចូរប្រាកដថាព្រះជាព្រះដ៏ពិត។*

2 ហើយឥឡូវនេះព្រះអង្គអើយសូមប្រទានពរព្រះបន្ទូលទ្រង់ឲ្យបន្តរទៅមុខសូមឲ្យព្រះវិញ្ញាណបរិសុទ្ធចាប់យកចិត្តនិងគំនិតរបស់យើង ហើយរៀបចំយើងសំរាប់វត្តមានរបស់ទ្រង់ដែលយើងបានអញ្ជើញ។ ត្បិតយើងមិនមកដំណាក់ព្រះ គ្រាន់តែមើលឬឃើញនោះទេប៉ុន្តែគឺយើងមករៀនពីទ្រង់ និងស្គាល់ពីធម្មជាតិរបស់ ទ្រង់ និងផ្លូវរបស់ទ្រង់និង ហេតុផលរបស់ទ្រង់ ដើម្បីឲ្យយើងអាចប្រឈមនៅបញ្ហាផ្សេងៗក្នុងជីវិតដោយការធានាពិតប្រាកដជាព្រះដ៏ពិត។ សូមទទួលព្រះអង្គអើយ យើងទូល សូមនៅក្នុងព្រះនាមព្រះអម្ចាស់ ព្រះយេស៊ូវ។ អាម៉ែន។

3 វា គឺជាព្រឹកមួយដែលគួរឲ្យខ្លាច។ វាក្តៅខ្លាំងហើយមានធូលីដីទៀត ហើយមានមនុស្សនៅផ្លូវជាច្រើន បានស្លាប់ដោយសារអត់ឃ្លាន ហើយផែនដីឡើងកំដៅកាន់តែក្តៅឡើងៗ ហើយជិតនឹងឆេះដែរ។ ការទាំងអស់នេះបានឆ្លុះបញ្ចាំងឃើញពីជីវិតដ៏ពុករលួយរបស់គេម្នាក់ៗ។

4 អ្នកឃើញទេ ស្តេចអ័រហាប់គ្រងរាជ្យ—ក្នុងប្រទេសអ៊ីស្រាអែល នៅពេលនោះ ស្តេចអ័រហាប់ គឺជាស្តេចដ៏ឃោរឃៅជាងស្តេចដទៃទៀត ដែលបានគ្រប់គ្រងសាសន៍អ៊ីស្រាអែល។ គ្មានស្តេចណាឃោរឃៅជាងស្តេចអ័រហាប់ទេ ហើយព្រះបានបង្រៀនឲ្យទ្រង់ទទួលស្គាល់ការបរាជ័យដោយសារ ការមិនយក ព្រះជាធំនៅពេលដែលទ្រង់ធ្វើអ្វីមួយ។ ទោះបីជា ទ្រង់មានប្រព័ន្ធទាហានដែលខ្លាំងពូកែ និងប្រជា ជន មានការរីកចំរើនយ៉ាងណាក៏ដោយ ប៉ុន្តែអ្នកក៏មិនត្រូវបង្អាប់ព្រះជាម្ចាស់ដែលគង់នៅជាមួយទ្រង់តាំងពីដើមមកដែរ។

5 បន្ទាប់មកក្នុងការរៀបអភិសេករបស់ទ្រង់ ជំនួសឲ្យការរៀប អភិសេក ជាមួយប្រជាជនរបស់ទ្រង់ ទ្រង់បានរៀបអភិសេកជាមួយមហេសី ដែលមានបាបជឿលើអារក្សសាតាំងគោរពព្រះក្លែងក្លាយហើយដែលរំលងពីបំណងព្រះ ហរទ័យ របស់ព្រះ។ ទ្រង់បានរៀប អភិសេក ជាមួយនឹងនាងយេសិបិល ជាអ្នកដែលមិនជឿ លើព្រះជាម្ចាស់។

6 ហើយគ្មានអ្នកជឿណាម្នាក់រៀបការជាមួយ អ្នកមិនជឿ ក្រោមលក្ខខណ្ឌណាមួយឡើយ។ គេតែងតែរៀបការជាមួយនឹងអ្នកដែលជឿដូចគ្នា។

7 ប៉ុន្តែស្តេចអ័រហាប់បានធ្វើអំពើដ៏អាក្រក់នេះ។ ដោយគ្មានការសង្ស័យនោះទេ ប៉ុន្តែយេសិបិលស្រីដែលស្អាត។ ហើយទ្រង់លង់នឹងសម្រស់ ដែលមើលឃើញជំនួសឲ្យការដែលនាងប្រព្រឹត្ត។ នោះហើយជាអ្វីដែលប្រជាជន ប្រព្រឹត្តកំហុសដូចសព្វថ្ងៃ។

8 បន្ទាប់មកនាងយក ការថ្វាយបង្គំរូបចម្លាក់ចូលក្នុងប្រទេស ក្នុងចំណោមប្រជាជន។ ហើយប្រជាជន ពួកសង្ឃអ្នកបម្រើព័ន្ធកិច្ចគោរពហើយក្លាយជាជនរងគ្រោះ ដោយសារម្រូវការ ដ៏ពេញនិយមរបស់ពួកគេ។

9 ហើយវាគឺជារូបភាពដ៏អាក្រក់មួយនៃប្រទេសយើងសព្វថ្ងៃ ។ យើងបានធ្លាក់ទៅក្នុងតម្រូវការដ៏ពេញនិយម។ គ្មានអ្វីសង្ស័យដែលសង្ឃសម្រេចចិត្តថាមិនអីទេ

ដរាបណារដ្ឋាភិបាលយល់ស្របតាមដែរ។ តែខ្ញុំមិនខ្វល់ ថារដ្ឋាភិបាលយល់ស្រប ឬ មិន យល់ស្របតែសំខាន់ ព្រះយល់ស្របនឹងយើងឬអត់។ ហើយប្រជារាស្ត្រ គិតថាវាប្រហែល ជាមិនអីទេព្រោះពួកគេគិត ថាលោកិយ៍ គឺជាអ្វីៗរបស់ គេទៅហើយ។

10 ហើយប្រហែលមានមនុស្សម្នាក់ នឹងសួរខ្ញុំដើម្បីរំឭកឡើងវិញ នូវអ្វីដែលជារូបភាពយ៉ាងអាក្រក់នាពេលបច្ចុប្បន្ននេះ។ យើងប្រហែលមិនធ្លាប់ គិតថាយើងថ្វាយ បង្គំរូប ចម្លាក់ទេ ប៉ុន្តែគឺយើងកំពុងថ្វាយបង្គំហើយ។ ហើយរដ្ឋាភិ បាលបានទទួល វាដែរ។ មនុស្ស សព្វ ថ្ងៃភាគច្រើនជាអ្នកដែលថ្វាយបង្គំរូបព្រះ ព្រោះពួកគេ—ពួកគេ តែង តែថ្វាយ បង្គំរូប ព្រះក្លែងក្លាយជាច្រើន។ ពួកគេមួយចំនួនថ្វាយបង្គំតារា ភាព យន្ត ដូចព្រះ។ មួយចំនួនថ្វាយបង្គំលុយដូចព្រះ។ ហើយមួយ ចំនួនគោរព បូជាតារា ទូរទស្សន៍ ដូចរូបព្រះរបស់ពួកគេ។ ប៉ុន្តែអ្វីទាំងអស់ដែលអ្នកដាក់នៅចំពោះមុខព្រះជាម្ចាស់គឺជារូបសំណាកអនុញ្ញាតឲ្យកើតមានឡើងអ្វីក៏ដោយ។

11 សូម្បីតែសាតាំងដែលជាសត្រូវធំរបស់យើង គឺជាម្នាក់ដែលឆ្លាតរហូតដល់ពេលខ្លះវាដាក់ព្រះវិហារនៅចំពោះព្រះទៀតផង។ អ្នកប្រហែលជា អាចមាន ក្រុ ម ជំនុំដ៏ធំមួយ។ អាចជាអគារធំឬអាចជានិកាយយ៉ាងធំមួយ។ ហើយជា ថ្មីម្តងទៀត វាអាចជាក្រុមជំនុំដ៏ធំមួយ។ ប៉ុន្តែកុំអនុញ្ញាតអ្វីមក នៅក្នុងចិត្តរបស់ អ្នកមុនព្រះជាម្ចាស់ឡើយ។ អ្វីមួយដែលមុនព្រះគឺជារូបចម្លាក់។

12 ហើយមនុស្សទាំងនេះបានដឹងថាវិញ្ញាណរបស់ពួកគេមិនដូចពីមុនទេ ដូចជាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្តេចផ្សេងទៀត។ ហើយពួកគេមានគំនិតថា ពួកគេ គ្រាន់តែជាជាតិសាសន៍នៃសាសនាហើយអ្វីគ្រប់យ៉ាងគេគិតថាល្អ។ ហើយនោះ ជាផ្លូវមួយដែលយើងបានមកដល់ផងដែរ។

13 ប៉ុន្មានខែមុនខ្ញុំបាននិយាយ ជាមួយមិត្តភក្តិរបស់ខ្ញុំម្នាក់។ ហើយគាត់បាននិយាយថា "បងប្រុសប្រានហាំខ្ញុំជឿថា អ្នកទាញសហរដ្ឋអាមេរិកឲ្យចុះកាន់តែជិតណាស់ហើយ។" គាត់បាននិយាយថា "អ្នកតែងតែគ្រហឹម ដាក់អំពើបាបហើយ តើព្រះនឹងដាក់ទណ្ឌកម្មជាតិសាសន៍នេះយ៉ាងណា?។"

14 ខ្ញុំបាននិយាយថា "ទ្រង់ត្រូវតែធ្វើវាដើម្បីឲ្យវាយុត្តិធម៌។"

គាត់បាននិយាយថា "ប៉ុន្តែបងប្រុសប្រានហាំភ្លេចថាជាតិសាសន៍ នេះបានរកឃើញដោយបទគម្ពីរ។" ហើយពួកបុព្វបុរស របស់យើងបានមក នៅទីនេះហើយ ព្រះបានប្រទានឲ្យយើងនូវមរតកនេះ។ហើយយើងជាសាសន៍នៃសាសនា។

15 ខ្ញុំបាននិយាយថា "នោះគឺជាការពិត។ គ្មាននរណាម្នាក់ដឹងថាតើខ្ញុំ ពេញចិត្តប្រជាជាតិនេះប៉ុណ្ណានោះទេ! ប៉ុន្តែមើលទៅបងប្អូនអើយ អ៊ីស្រាអែលក៏ជា រាស្ត្រដែលព្រះជ្រើសរើសដែរហើយទ្រង់ក៏បានបញ្ជូនហោរា និងមនុស្សអស្ចារ្យមកដែរ។ ប៉ុន្តែព្រះមិនឈរនៅអំពើបាបនោះទេ។ ទ្រង់បាន ធ្វើឲ្យអ៊ីស្រាអែលបាន ច្រូតនូវអ្វី ដែលពួកគេបានសាបព្រោះ។ ហើយប្រសិនបើទ្រង់ បានធ្វើឲ្យ អ៊ីស្រាអែលច្រូតបានផលពីអ្វីដែលគេ បានព្រោះទ្រង់នឹងឲ្យយើងច្រូតអ្វីដែលយើងបានសាបព្រោះដែរ។ ទ្រង់មិនបានឲ្យផលទៅមនុស្សណាដែល មិនបានគោរពទ្រង់នោះទេ។"

16 ហើយយើងមានកន្លែងមួយគិតថា ដោយសារយើងសម្រាកនៅអ្វី ពួកបុព្វបុរស របស់យើងបានធ្វើ ឬនៅលើអ្វីដែលជាគ្រឹះមួយយ៉ាងធំនៃព្រះវិហារជាអ្វីដែលបានបូជាទៅកាន់ព្រះ ដែលត្រឹមត្រូវនឹងអបអរបំផុត។ ប៉ុន្តែយើងមិនអាច ទាញសេចក្តី សង្គ្រោះពីទង្វើរបស់ពួកគេ បានទេ! សេចក្តីសង្គ្រោះជាកិច្ចការរបស់បុគ្គលរវាងមនុស្សម្នាក់ៗជាមួយនិងព្រះ។ មិនមែនជាមួយនឹងប្រទេសរបស់យើងជាមួយក្រុមជំនុំរបស់យើង ប៉ុន្តែជាមួយនឹងខ្លួនយើង ចំពោះព្រះជាម្ចាស់ យើងឆ្លើយ។

17 វាបានមកដល់កន្លែងមួយនៅក្នុងប្រទេសរបស់យើងរហូតដល់នៅ កណ្តាលបំផុតនៃវិញ្ញាណរបស់យើង អ្នកចូលទៅកាន់វិញ្ញាណបុរសនិងស្ត្រីហើយ អ្នកនឹ ងឃើញចិត្តរបស់ពួកគេ នៅមានអ្វីមួយដែលខ្វះ។

18 យើងបាន មកក្នុងប៉ុន្មានសប្តាហ៍មុននេះ ខ្ញុំបានយល់ពីរឿងទាំងនេះ ហើយឃើញថាបុរសនៅក្នុងគំនិតខ្ញុំគាត់ជាមនុស្សដែលមានចិត្តរឹង នៅឡើយទេខ្ញុំឃើញថាពួកគេកំពុងផ្តោតលើសាច់ឈាម នឹងដើរជុំវិញគេ ហើយបាន និយាយថា "ព្រះផ្តល់ឲ្យខ្ញុំធំបំផុត*ដូច្នេះ–និង–ដូច្នេះ*។ ព្រះឲ្យ..." អ្នកជាមនុស្សកំពុត។

19 សម្ភារះអស្ចារ្យមិនមែនតែងតែនៅក្នុងព្រះហប្ញទ័យរបស់ព្រះទេ។ ព្រះជាម្ចាស់បានធ្វើសេចក្តីជំនឿហូរដូចភ្លៀងធ្លាក់លើមនុស្សសុចរិតនិងមនុស្សទុច្ចរិត។ ប៉ុន្តែអ្វីដែល ពិភពលោកត្រូវការនាពេលបច្ចុប្បន្ននេះ មិនមែនជាជំនឿបញ្ឆោទនោះទេ តែព្យាយាមបោកបញ្ឆោតខ្លួនឯងចូលទៅក្នុងអ្វីមួយ ហើយហៅថាដោយវិញ្ញាណ។

20 ពេលខ្លះ ជំនឿ នឹងធ្វើទីសំគាល់យ៉ាងធំ ហើយនៅតែមិនបានមកពីចិត្ត នៃ វិញ្ញាណនោះទេ។ តើព្រះអម្ចាស់របស់យើងមិនបាននិយាយដូច្នេះទេឬអី? "មនុស្ស ជាច្រើននឹងមករកអញនៅថ្ងៃនោះហើយនិយាយថា 'តើខ្ញុំមិន បាន ធ្វើ*នេះ* ហើយ*នោះ* ក្នុងព្រះនាមរបស់ទ្រង់ទេឬអី?' ហើយអញ នឹង ឆ្លើយទៅគេថា 'ចាកចេញ ពីអញទៅអ្នក ប្រព្រឹត្តអំពើទុច្ចរិតអើយ។'" តើអ្វី ទៅជា អំពើទុច្ចរិត? គឺជាអ្វីដែល អ្នកដឹងថាត្រឹមត្រូវតែអ្នកមិនធ្វើ។ "អញមិនដែលស្គាល់ឯងទេ" ទ្រង់នឹងមានបន្ទូលដូច្នេះ។ ហើយយើងកំពុងរស់ នៅក្នុងថ្ងៃនោះដែរ។

21 អ្វីដែលយើងត្រូវការនាពេលបច្ចុប្បន្ននេះ គឺមិនមែនជាសម្ភារៈនោះទេ។ យើងមានរបស់ទាំងនោះហើយ។ យើងមិនត្រូវការព្រះវិហារកាន់តែច្រើន។ យើងមិនត្រូវការក្រុមជំនុំកាន់តែច្រើនទេ។ យើងមិនត្រូវការបន្ថែមទៀត លើវិទ្យុ និងទូរទស្សន៍។ យើងមិនត្រូវការរបស់ជាច្រើនទាំងនេះទេ។ ប៉ុន្តែអ្វីដែលយើង ត្រូវការនៅថ្ងៃនេះ គឺព្រលឹងវិញ្ញាណគឺជាមនុស្សដែលនឹងបន្ទាបខ្លួននៅ ចំពោះ ព្រះ ទោះបីពួក គេ មិនបានទទួលប្រាក់មួយកាក់ក៏ដោយហើយគេនឹងអធិស្ឋាន រហូតដល់វិញ្ញាណនោះគង់នៅក្នុងចិត្តរបស់ពួកគេដោយការពេញចិត្តនឹងសេចក្តីល្អនៃព្រះជាម្ចាស់ ហើយការរីកផុសផុលនឹងនៅក្នុងចិត្តរបស់ពួកគេដែលផ្លាស់ប្តូរឥរិយាបទ និងបរិយាកាសដែលពួកគេរស់នៅ។

22 អ្នកអាចនឹងមិនមានស្បែកជើងពាក់ លើជើងរបស់អ្នក អ្នកអាចនឹង មានសម្លៀក បំពាក់ រហែកប៉ុន្តែអ្វីដែលសំខាន់ ក្នុងចិត្តរបស់អ្នកគឺអ្នកច្រៀងសរសើរ តំកើង ព្រះជាម្ចាស់រហូត។ ខ្ញុំចង់មានការសរសើរជាជាងមានលុយ ច្រើនលើពិភពលោក។

23 ដូច្នេះអ្នកមិនអាចនិយាយថារបស់ធម្មជាតិ ជាទីសំគាល់នៃព្រះពររបស់ព្រះ។ ដេវីឌ បាន និយាយទៅ ព្រះជា ម្ចាស់ថា លោកបានឃើញមនុស្សអាក្រក់ឈរនៅចំពោះមុខរបស់លោក...ដូចជា ដើមឈើមានស្លឹកអស្ចារ្យ។ ប៉ុន្តែព្រះជាម្ចាស់ បានសួរ លោកថា "តើអ្នកមិន ធ្លាប់ គិត ពីទ្រង់នៅទីបញ្ចប់របស់អ្នកទេឬអី?" មិនថាសម្លៀក បំពាក់ល្អដែលយើងស្លៀកល្អប៉ុណ្ណា តើយើងត្រូវញាំប៉ុណ្ណា នោះមិនមែនជាអ្វីដែលនៅក្នុងវត្តមានរបស់ព្រះឡើយ។ រាងកាយដែលយើងរស់នៅក្នុងក្តីវិនាសមិនដឹងថាត្រូវធ្វើយ៉ាងណាមិនឲ្យវាឆាប់ពុករលួយឡើយ។ ប៉ុន្តែវាជា ព្រលឹងដែល

នៅក្នុងមនុស្សនេះវាជាលក្ខខណ្ឌនៃព្រលឹងវិញ្ញាណ ដែលធ្វើចលនាចូលទៅក្នុងវត្តមានរបស់ព្រះដ៏មានព្រះជន្មរស់។

24 ប៉ុន្តែយើងយកជា ប្រយោជន៍ផ្ទាល់ខ្លួន។ យើងគិតថាដោយសារការនោះយើងបានជាជាតិសាសន៍មួយ...ដូច្នេះស្តេចអ័រហាប់និងជនជាតិអ៊ីស្រាអែលទាំងអស់នៅថ្ងៃនោះ បានយកអ្វីៗទាំងអស់ជាប្រយោជន៍ គ្រប់យ៉ាង គឺត្រឹម ត្រូវ ទាំង អស់។ ពួកបូជាចារ្យនិងគ្រូអធិ ប្បាយ របស់ពួកគេបានព្យាយាម ប្រាប់ ពួកគេ ថា "អ្វីទាំងអស់គឺជាការល្អ។" អ្វីគ្រប់យ៉ាងគឺល្អទាំងអស់។ ប៉ុន្តែមានម្នាក់ក្នុងចំណោមពួកគេបានស្រែកយំប្រឆាំងនឹងអ្វី ដែលខុសនោះព្រោះម្នាក់ នេះ ដឹងថាព្រះជាម្ចាស់ ដ៏បរិសុទ្ធ មិនពេញចិត្តជាមួយនឹង សម័យកាលទំនើប និងនិន្នាការពីសាសនា មិនបរិសុទ្ធទេ។

25 ដូច្នេះព្រះនៃឋានសួគ៌នៅតែមាននៅពេលបច្ចុប្បន្ននេះដូចគ្នា។ នៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់យើងនិងរឿងធំដែលយើងកំពុងតែព្យាយាមធ្វើព្រះនឹង មិនរីករាយចំពោះជីវិតដែលញែកការបរិសុទ្ធចេញពីទ្រង់ឡើយ។

26 យើងអាចកសាងសាលារៀន ទីសក្ការៈបូជា និងរោងឧបោសថ។ យើងអាចមានអង្គការ។ យើងអាចធ្វើអ្វីដែលអស្ចារ្យ ប៉ុន្តែព្រះជាម្ចាស់នឹង មិនសព្វព្រះទ័យលុះត្រាតែព្រលឹងមនុស្សបានញែក ជាបរិសុទ្ធនៅលើអាសនៈ របស់ព្រះជាម្ចាស់ញែកសំរាប់ការងាររបស់ព្រះ។ ហើយអ្នកមិនអាចរកឃើញអ្វីផ្សេងទៀតទេ។

27 អ្នកឃើញការប្រជុំអធិស្ថាននៅទន់ខ្សោយ ការអធិស្ឋានត្រឹមតែមួយនាទីនាំ គ្នាចូលដំណេក។ យើងឃើញថាមានការប្រជុំម្តងឬពីដងតែប៉ុណ្ណោះ ក្នុងមួយថ្ងៃ។ នៅពេលដែលយើងទាំងអស់គ្នា បានប្រព្រឹត្តកំហុស។ ប្រជាជាតិរបស់យើងសីលធម៌ត្រូវបានធ្លាក់ចុះ។ យើងមានពាក្យរបស់លោកប៊ីលីហ្គ្រាហាំ និង អូរ៉ាល់រូប៊ីត នៅគ្រប់ទីកន្លែង។ ប៉ុន្តែរហូតមកដល់ពេលនេះមានការស្រេកឃ្លាននៅក្នុង ចិត្តរបស់ប្រជាជនអាមេរិកមួយចំនួន ដើម្បីនាំវាត្រលប់ទៅឯព្រះជាម្ចាស់វិញម្តងទៀត ដើម្បីបទពិសោធនៃការរស់នៅក្នុងសេចក្តីជំនឿមិនស្លាប់មួយក្នុងព្រះដ៏រស់យើងគឺគ្រាន់តែវាយខួរក្បាលរបស់យើង និយាយថាចេញមក។

28 យើងអាចនឹងនៅតែដើរជាមួយអំនួតរបស់យើង ជាមួយនឹងការងាកត្រឡប់ចុះ មកតាមផ្លូវ និង បំណងប្រាថ្នាមួយ ដើម្បីក្លាយជា "បណ្ឌិត" ឬ "បូជាចារ្យ"។ យើងអាចជាគ្រូគង្វាលសម្រាប់ក្រុមជំនុំធំបំផុត ដែលមាន នៅលើលោកិយ៍ ហើយ

យើងអាចគោរព ប្រណិប័តន៍ព្រះ ដែលយើងអាចគោរព ហើយគ្មាននរណាម្នាក់អាចបញ្ជា នៅលើជីវិតរបស់យើងបានទេ។ ប៉ុន្តែរហូតដល់ព្រលឹងរបស់យើងបាន ឆេះឆួល ដូចជាភ្លើង សម្រាប់ព្រះជាម្ចាស់ រហូតដល់មនុស្សម្នាក់ដែល នៅទីនោះមានក្តីប្រាថ្នានៅចំពោះទ្រង់! "ដូចជាចិត្តដែលស្រែកដង្ហក់រកទឹកជ្រោះហើយព្រលឹងខ្ញុំស្រែក តាមរកទ្រង់។" រហូតដល់យើង ទទួលបានបទពិសោធមួយ!

29 ហេតុនេះបានជាកុំម្មុយនីស្តនិងផ្សេងទៀតនឹងទទួលបានផលពីដីដែលពួកគេ កំពុងធ្វើ ហើយការចូលរួមទាំងអស់ដែលយើងអាចធ្វើបាន នឹងមិនអាចបញ្ឈប់វាបានទេ។ វាជាការព្យាករថានឹងកើតមាន។ ប៉ុន្តែព្រះជាម្ចាស់បាន ត្រាស់ហៅយើងទៅឯព្រះវិហារទ្រង់។

30 តើធ្វើដូចម្តេចបានជា ស្រ្តីតូចម្នាក់នេះត្រូវបាន បង្ហាញដល់លោកអេលីយ៉ា! ពីព្រោះជាធម្មតាសកម្មភាពរបស់អ្នកបានបង្ហាញពីអ្វីដែលអ្នកមាន។ ហើយជាថ្មីម្តងទៀតនាងត្រូវបានជ្រើសរើសឲ្យកំសាន្តចិត្តហោរារបស់ព្រះ។ សូមចាំថានាងជាសាសន៍ដទៃមិនមែនជាសាសន៍យូដាទេ។

31 ហើយដីនេះត្រូវបានឆេះឡើង។ ហើយគ្មានការសង្ស័យដែលថាស្រ្តីតូច នេះអ្នកពូកែ ជាប្រភេទនៃអ្នកជឿ...ព្រោះយើងឃើញថាព្រះជាម្ចាស់ នឹងមិនហៅនាងប្រសិន បើ នាងមិន មានភាពសក្តិសមមួយដើម្បីកំសាន្តហោរារបស់ព្រះ។ ដ្បិតទ្រង់ មិន ដែលចាត់ហោរា របស់ទ្រង់ដើម្បីទៅផ្ទះនោះ សម្រាប់ការមិន សក្តិសមនោះទេ។

32 វាមិនមែនជាការជ្រើស រើសរបស់គាត់ទេ។ វាគឺជាការជ្រើស រើសរបស់ព្រះ។ វាមិនមែននាងបង្គាប់គាត់ទេ។ តែជាព្រះបង្គាប់គាត់។ លោក បាន ស្នាក់នៅឯជ្រោះ មួយ។ នោះក្អែកបានផ្តល់ម្ហូបដល់លោក។ ប៉ុន្តែវាជា ការបញ្ជារបស់ ព្រះជា ម្ចាស់ ដើម្បីឲ្យ អ្វីមួយកើត ឡើងបាន។ ហើយព្រះទ្រង់ដឹងប្រាកដថា អ្នកជឿ ក៏មាន និស្ស័យដូចលោកលោកអេលីយ៉ាដែរ។

33 នាងជាស្ត្រីមេម៉ាយម្នាក់។ ហើយយើងទាំងអស់គ្នា ដឹងថាស្រ្តីមេម៉ាយម្នាក់នឹងត្រូវបានឆ្លងកាត់ការរស់នៅជាមួយប្តីរបស់នាង ដែលប្តីរបស់នាងបានស្លាប់ទាំងវ័យក្មេងម្នាក់។

34 ហើយនៅទីនោះពួកគេរស់នៅអាស្រ័យលើផលដំណាំរបស់ពួកគេ។ ពួកគេមិនមានគម្រោងដូចជាយើងមានសព្វថ្ងៃនេះនោះទេ និង—និងការការពាររុក្ខជាតិ

ទេ។ ពួកគេបានអាស្រ័យ លើផលដំណាំរបស់ពួកគេ។ ហើយដោយសារអំពើ
ទុច្ចរិត និង ការ ខូចសីលធម៌របស់ពួកគេបាននាំឲ្យ មានគ្រោះរាំងស្ងួតលើដី នៅ ទី
នោះពួកគេទាំងអស់ឃ្លានយ៉ាងខ្លាំងនិងស្លាប់ជាច្រើននាក់។

35 ហើយបន្ទាប់មកយើងឃើញថាគ្មានការសង្ស័យទេដែលនាងអធិស្ឋានពីមួយ
យប់ ទៅមួយយប់ យប់នោះខណៈ ដែលនាង បានចាប់ផ្តើម មើលឃើញ ថា ម្សៅ
ក្នុងធុង របស់នាងនឹងស្រកចុះទៅៗ។ ហើយវាត្រូវដល់ស្ថានភាពមួយ ដែល
សូម្បី តែ ម្សៅមួយពែងក៏មិនពេញផងក្នុងធុង។ អ្វី ដែល នាងមាន គឺមួយក្តាប់ តូច
តែប៉ុណ្ណោះ។ សេចក្តីស្លាប់បានចូលជិតទៅនឹងមាត់ទ្វាររបស់នាង។ សម្រាប់ការ
នេះគ្មានវិធីណាដែលអាចរកម្សៅបានទៀតទេ។ ប្រជាជាតិទាំងមូលត្រូវបានស្រេក
ឃ្លានយ៉ាងខ្លាំង។

36 ហើយប្រេងសល់ តែមួយស្លាបព្រាប៉ុណ្ណោះ ដែលនៅក្នុងធុងតូចនោះ។ ត្រឹម
តែប្រេងនិងម្សៅប៉ុនេះបានដាក់នាងនៅចន្លោះការស្លាប់នោះ។ នាងត្រូវតែ មានការ
អធិស្ឋានដោយស្មោះត្រង់ពិតប្រាកដ។ អ្នកបានអនុញ្ញាតការនេះកើត មាន នៅផ្ទះ
របស់អ្នក វាជាការស្មោះត្រង់ជាងព្រឹកនេះបន្តិច នៅពេលដែលយើងដឹងថា សេចក្តី
ស្លាប់នៅឯមាត់ទ្វា។

37 ហើយខ្ញុំជឿថាប្រហែល ជានាងនឹងគិតថា ប្រហែលជានាងបានអធិស្ឋាន
ពេញមួយយប់ហើយដើម្បីដោះ ស្រាយបញ្ហានោះសម្រាប់មួយថ្ងៃទៀត។ នាង
ក្រលេកមើលបបូរមាត់ដ៏ស្លេករបស់កូនប្រុសតូចរបស់នាងមានអាយុ ប្រហែលបី
ឬបួនឆ្នាំ។ ហើយនាងអាចមើលឃើញការធ្លាក់ចុះស្គមដូចជា មានមនុស្ស ដកអ្វី
ពីគេ។ ហើយវាត្រូវជារឿងគួរភ័យខ្លាចដែល ជាម្តាយនេះបានឃើញហេតុការណ៍
ទាំង នេះកើតឡើងដល់កូន។ ហើយនាងនៅតែអធិស្ឋានដល់ព្រះអង្គម្ចាស់ ទាំង
យប់ទាំងថ្ងៃ "ឥឡូវនេះយើងមានម៉្សៅមួយក្តាប់តូច និងប្រេងមួយ ស្លាបព្រា។"

38 អ្នកបានដឹងហើយថា វាជារឿងចម្លែកមួយ។ សូមព្រះទ្រង់អាចនឹងអនុញ្ញាត
ការ មួយកើតឡើងក្នុងចំណោមអ្នករាល់គ្នា បើសិនជាអ្នកមិនដែលលឺខ្ញុំអធិប្បាយ
ម្តងទៀត។ ចូរឲ្យនេះជាសារមួយ។ វាជាការចម្លែក ហើយចម្លែកបំផុតដែលពេល
ខ្លះព្រះជាម្ចាស់បានធ្វើតាមវិធីនោះ។

39 អ្នកបានដឹងហើយថា នៅពេលដែលយើងបានសារភាពអំពើបាបរបស់យើង
ហើយបានជួបព្រះជារៀងរាល់ថ្ងៃ ជាតម្រូវការដែលព្រះទ្រង់តម្រូវ...យើងជឿ លើ

ព្រះ។ មានកាលៈទេសៈមួយដែលយើងត្រូវជួបប្រជុំគ្នាហើយជាបំណង ព្រះហរទ័យ របស់ទ្រង់។ ហើយយើងបានសារភាព អំពើបាបរបស់យើង ដែលយើង បាន ធ្វើ ខុសទាំងអស់ចំពោះព្រះ។ រាល់តម្រូវការដែលព្រះបានដាក់ឲ្យយើង ធ្វើឬ ទ្រង់តម្រូវឲ្យយើងមាន ការស្មោះស្ម័គ្រជាមួយទ្រង់ដែរ។ ទ្រង់គ្រាន់ តែមិន ឆ្លើយ នឹងយើង។

40 ខ្ញុំប្រាកដថាខ្ញុំកំពុងនិយាយទៅកាន់មនុស្ស នៅព្រឹកនេះដែលបានមកដល់កន្លែងនោះ។ ខ្ញុំស្ថិតក្នុងស្ថានភាពនោះជាច្រើនដងដោយខ្លួនឯង។ នៅពេលដែល ខ្ញុំបាន គិតទៅវិញទៅមកការឆ្លុះបញ្ចាំងពីជីវិតរបស់ខ្ញុំ រាល់ថ្ងៃហើយខ្ញុំបានរក ឃើញ ថាខ្ញុំ បានធ្វើអ្វីមួយខុសខ្ញុំក៏ចូលទៅសារភាពវាចំពោះព្រះហើយនិយាយថា "ព្រះអម្ចាស់ដ៏ជាព្រះ ខ្ញុំនឹងប្រព្រឹត្តល្អ" ហើយខ្ញុំនឹងធ្វើវាដូច្នេះរហូត។ បន្ទាប់មក ត្រឡប់ មក និយាយជាថ្មីម្តងទៀតថា "ឥឡូវនេះព្រះអម្ចាស់ទ្រង់ជាព្រះ ទ្រង់នឹង ឆ្លើយតបមកទូលបង្គំ។ ពិតណាស់ខ្ញុំបានទទួលរាល់សំណើរ ទាំងអស់ដែលទ្រង់ បាន តម្រូវខ្ញុំ ធ្វើ។ និងរាល់តម្រូវការខ្ញុំបានទទួលវា។" ហើយទ្រង់នៅតែមិនឆ្លើយតបនឹង មិនផ្លាស់ប្តូរហាក់បីដូចជាស្ងៀមស្ងាត់ នោះហើយជាពេលដែលអ្នកទទួល បាន ដើម្បី ប្រាកដថាទ្រង់ជាព្រះ។ កុំបាក់ទឹក ចិត្តឲ្យសោះ។ រឿងមួយ គត់គឺថា នៅក្នុងដួងចិត្តរបស់អ្នកចូរប្រាកដថាព្រះជាព្រះដ៏ពិត។

41 អត្ថបទរបស់ខ្ញុំ។ ត្រូវតែដាក់លាក់ជាទីមួយមុននឹងអ្នកធ្វើអ្វីមួយ។ ចូរ ប្រាកដក្នុងចិត្តរបស់អ្នកថាទ្រង់ជាព្រះពិត។ ហើយនៅពេលដែលអ្នកបានជួបអ្វីគ្រប់យ៉ាងដែលទ្រង់បានមានបន្ទូល បន្ទាប់មកអ្នកប្រាកដថាទ្រង់ជាព្រះ ហើយជាពេលដែលជំនឿ បានប្រព្រឹត្តនៅទីនោះ។ សេចក្តីជំនឿឈរ ស្ថិតស្ថេរ សម្រាប់ការដែលអ្នកដឹងថាទ្រង់គឺជាព្រះ។

42 ហើយជួបគ្រប់តម្រូវការ។ អ្នកជឿថាទ្រង់ជាព្រះ ហើយជំនឿនៅខ្ជាប់ខ្ជួន។ អូសូមសរសើរព្រះនាមទ្រង់! សេចក្តី ជំនឿនឹង មិនផ្លាស់ប្តូរ វាជាការ ប្រាកដ ថាព្រះគឺជាព្រះដ៏ពិត ព្រះនិងប្រទានរង្វាន់ដល់ អស់អ្នកណាដែលស្វែងរកទ្រង់។

43 សូមឲ្យជំនឿនេះចូលជ្រៅហើយមិនផ្លាស់ប្តូរពីអ្នកទេរោងឧបោសថប្រានហាំ។ បើសិនជាអ្នកបំពេញតាមតម្រូវការរបស់ព្រះ ហើយនៅក្នុងចិត្តរបស់អ្នកអ្នក ជឿ ថាទ្រង់គឺជាព្រះ ព្រះគ្រាន់តែសាកល្បងសេចក្តីជំនឿរបស់អ្នក តែប៉ុនោះទ្រង់ សព្វ ព្រះ ទ័យនឹងធ្វើបែបនោះ។ អ្នកសារភាពអំពើបាបរបស់អ្នក ហើយអ្នក

បានបំពេញតាមតម្រូវការដែលព្រះឲ្យ បំពេញ ហើយទ្រង់នៅតែបន្តនៅស្ងៀម ចាំទតមើលសេចក្តីជំនឿរបស់យើង ដែលថាទ្រង់គឺជាព្រះពិត។ បន្ទាប់សេក្តីជំនឿនៅជាប់ ជានិច្ចទោះបីមិនដឹងថាវាជាអ្វីក៏ដោយ ប៉ុន្តែវាស្គាល់ថាទ្រង់ជា ព្រះហើយវាប្រាកដ ថា ព្រះទ្រង់ជាព្រះពិត។

44 បន្ទាប់មកសូមចាំថាបើជាទ្រង់ជាពិត ព្រះបន្ទូលរបស់ទ្រង់ក៏ជាការពិតដែរ។ ហើយប្រសិនបើទ្រង់ ទាមទារអ្នកជួបកាលៈទេសៈទាំងនេះ ហើយទ្រង់ត្រូវមានកាតព្វកិច្ចដើម្បីថែរក្សាព្រះបន្ទូលរបស់ទ្រង់។ កុំឲ្យបែរចេញ ហើយនិយាយថា "ខ្ញុំមិនដែលបានប្រោសឲ្យជានោះទេ។ខ្ញុំ...។" អូ! អ្នកមានជំនឿទន់ខ្សោយអើយ។ កុំជឿថាអ៊ីចឹងអី។ ប្រសិនបើមានអ្វីត្រូវសារភាព និងអ្វីគ្រប់យ៉ាងបានរំលង ដោយអ្នកមិនបានទូលដល់ព្រះ អ្នកត្រូវមានសេចក្តីជំនឿចំពោះព្រះសិន។ គ្មានអ្វីនឹងអាចផ្លាស់ប្តូរបានទេ។ អ្នកបានប្រាកដថាទ្រង់គឺជាព្រះពិត។ "ពួកគេមាន សង្ឃឹមលើព្រះអម្ចាស់នឹងបន្តឲ្យកាន់តែរឹងមាំក្នុងសេចក្តីជំនឿរបស់គេ។ ពួកគេ នឹងឡើងជាមួយនឹងស្លាប ដូចសត្វឥន្ទ្រី។ ពួកគេនឹងរត់ទៅ ឥតដែលហត់ ប្រសិនបើពួកគេដើរក្នុងសេចក្តីជំនឿ ពួកគេនឹងមិនបាក់ទឹកចិត្តឡើយ។"

45 ចាំមើលនៅពេលដែលអ្នកបំពេញតម្រូវការរបស់ទ្រង់។ ដែលនាំសេចក្តីជំនឿរបស់អ្នកទៅ ក្នុងការសាកល្បង។ ប្រសិនបើបានជួប...ការបំពេញ របស់ ព្រះត្រូវបានធ្វើឡើង ហើយអ្នកបានពិចារណាវាយ៉ាងល្អិតល្អន់ ហើយអ្នកបានធ្វើអ្វី គ្រប់យ៉ាងតាមផែនការដែលព្រះបានប្រើអ្នក។ បន្ទាប់មកសេចក្តីជំនឿអាស្រ័យ លើការជឿរបស់អ្នកថាទ្រង់គឺជាព្រះពិត។ ចូរប្រាកដថាព្រះគឺជាព្រះដ៏ពិត។

46 អ្នកបានដឹងថាទ្រង់សព្វ ព្រះទ័យនឹងសាកល្បងយើង។ ទ្រង់ ចង់ឃើញ ពីប្រតិកម្ម សេចក្តី ជំនឿរបស់អ្នក។ តើ អ្នកដឹង ទេ? ព្រះចង់ឃើញពីរបៀប ប្រតិកម្មរបស់យើង។ នៅពេលអ្នកនិយាយថា "ឱព្រះអម្ចាស់អើយខ្ញុំជឿទ្រង់។ ទ្រង់ជាព្រះសង្គ្រោះ យើងខ្ញុំ។ ខ្ញុំ ជឿ ថាទ្រង់គឺជា អ្នកព្យាបាល ។ ខ្ញុំជឿថាទ្រង់គឺជាព្រះមួយអង្គ ដែលផ្តល់ព្រះវិញ្ញាណបរិសុទ្ធ។ ហើយព្រះបានប្រទាន នូវអ្វីដែលខ្ញុំត្រូវការ។" ហើយ បន្ទាប់មក នៅពេលដែលអ្នក សារភាពអំពើបាបរបស់អ្នកទាំងអស់ ហើយសន្យានឹងព្រះ នូវអ្វីដែលអ្នកបានធ្វើ បើទ្រង់អនុញ្ញាតឲ្យអ្នកធ្វើ អ្នកមិនបានធ្វើតាមព្រះ ហើយអ្នករត់គេចទៅ កន្លែងណា មួយឆ្ងាយពីព្រះ។ ព្រះជាម្ចាស់មិន អាច ប្រើអ្នកឱ្យធ្វើដូច្នោះទេ។ គ្មានផ្លូវណាឡើយ សម្រាប់ទ្រង់ក្នុងការប្រើប្រាស់ អ្នក។ ទ្រង់

មិនឆ្លើយនឹងអ្នកទេ ព្រោះទ្រង់បានដឹងពី សេចក្តីជំនឿរបស់អ្នកហើយ។ បន្ទាប់មកមួយរំពេច អ្នកចាកចេញទៅ ហើយទ្រង់មិនឆ្លើយតបនឹងអ្នក។ ប៉ុន្តែការពិតជំនឿពិតប្រាកដគឺជឿថាទ្រង់គឺជាព្រះជាម្ចាស់។ ចូរប្រាកដថាព្រះគឺជាព្រះដ៏ពិត។

47 ហើយប្រសិនបើព្រះធ្វើឲ្យការនេះបានកើតឡើង ដើម្បីឲ្យអ្នកសារ ភាព អំពើបាបរបស់អ្នកជាដើមហើយអ្នកបានធ្វើវា ជំនឿបានប្រាប់អ្នកថាទ្រង់ពិតប្រាកដ ជាព្រះ វានឹងកើតឡើងមែន។ សំណើរបស់អ្នក ត្រូវបានទទួល។ អូ ខ្ញុំ—ខ្ញុំសង្ឃឹមថាអ្នកមិនខកខានវាទេ។ ប្រសិនបើអ្នកច្បាស់ជាមួយព្រះជាម្ចាស់ ព្រះនឹងច្បាស់ ពីព្រះបន្ទូលរបស់ទ្រង់។ គ្រាន់តែរងចាំការសាកល្បងប៉ុនោះ។

ទ្រង់បានធ្វើវាច្រើនដងហើយ។ ចូរសាកល្បងមួយឬពីរករណី។

48 ចូរយើងគិតពី កូនរបស់សាសន៍ហេព្រើ។ ពួកគេមិនបានគោរពរូបសំណាកទេ។ ព្រះមានទំនុកចិត្តនៅក្នុងពួកគេ។ ហើយនៅពេលដែលពួកគេឮថា ពួកគេត្រូវចូលទៅក្នុងគុកភ្លើងដែលក្តៅនិយាយ "ព្រះរបស់យើងគឺអាចរំដោះយើងពី គុកភ្លើងនេះបាន។ ប៉ុន្តែប្រសិនបើទ្រង់មិនបានរំដោះយើងទេយើងក៏មិនទៅគោរពព្រះដទៃទៀតដែរ។" អ្នកឃើញទេពួកគេបានប្រាកដជាក់លាក់ថាព្រះគឺជាព្រះដ៏ពិត។

49 ពួកគេបានដឹងថា ទ្រង់ជាព្រះយេហូវ៉ា។ ពួកគេបានដឹងថាព្រះអង្គមាន ព្រះបន្ទូលតបការអធិស្ឋាន។ ប៉ុន្តែ ថាតើទ្រង់បានឆ្លើយតបក្នុង សេចក្តីដែលពួកគេអធិស្ឋានឬអត់ វាត្រូវតែជាសេចក្តីល្អ។ ដូច្នេះពួកគេគ្រាន់តែថ្លែងសារភាពអំពើបាបរបស់ខ្លួន ហើយដើរ ចូលទៅក្នុងសេចក្តីស្លាប់។

50 ពេលពួកគេបានចូលទៅក្នុងគុកភ្លើងដោយដឹងជាក់លាក់ថា ព្រះទ្រង់នឹង មិនអនុញ្ញាតឆេះពួកគេទេទ្រង់នឹងប្រោសពួកគេឲ្យរស់ឡើងវិញជាថ្មីម្តងទៀត។ ពួកគេទទួលថាព្រះជាព្រះជាម្ចាស់ដ៏ពិតដោយសារ ពួកគេបានដឹងថា ព្រះទ្រង់ នឹងធ្វើអ្វីគ្រប់យ៉ាង សម្រាប់រំដោះពួកគេ។ ហើយនៅពេលដែល យើងដឹងថា ព្រះជាម្ចាស់បានធ្វើការអ្វីគ្រប់យ៉ាងសម្រាប់សេចក្តីល្អរបស់យើង។

51 ដូច្នេះពួកគេបានថ្លែងសេចក្តីមួយ។ ពួកគេមានជំនឿពិត ហើយពួកគេបានដើរចូលទៅក្នុងគុកភ្លើងនោះ។ ហើយព្រះឲ្យពួកគេដើរចូលទៅ សម្លឹងមើល ទតមើល ទៅពួកគេ។ ទ្រង់ ចង់ឃើញពីប្រតិកម្មរបស់ពួកគេ។

52 ពេលនោះស្តេចមានបន្ទូល "តើអ្នកបានគោរពនៅពេលដែលត្រែផ្លុំ ឡើងទេ?"

ពួកគេបាននិយាយថា "ទេ។ យើងមិនគោរពទេ។" សេចក្ដីជំនឿរបស់យើងត្រូវកាន់ឲ្យជាប់។

"ប្រសើរណាស់ប្រសិនបើ អ្នកមិនបានលុតជង្គង់ ចុះតើអ្នកស្គាល់ច្បាប់ របស់យើងទេ?"

"មែនយើងស្គាល់ច្បាប់ របស់លោក។"

"ក្រិត្យវិន័យរបស់យើងគឺថាគុកភ្លើងនឹងត្រូវបានក្ដៅជាងប្រាំពីរដង ដែលមិនធ្លាប់មាន ហើយយើងនឹង បញ្ជូនអ្នកទៅទីនោះ។ តើឥឡូវនេះអ្នកចង់ គោរពទេ?"

"ទេ។ យើងនឹង មិនគោរពទេ។" នោះជាជំនឿ របស់ពួកគេ។

53 ព្រះមានបន្ទូលថា "អញនឹងឃើញអ្វីដែលពួកគេធ្វើ។ អញ នឹងឃើញពី ជំនឿរបស់ពួកគេមាន។"

54 ដូច្នេះទ្រង់មានបន្ទូលថា "ចងដៃចងជើងរបស់ពួកគេ ហើយចាប់ផ្ដើមឲ្យ ពួកគេដើរចូលគុកភ្លើងនោះ។" ហើយពួកគេបានដើរ លើភ្លើងដែលឆេះនោះ នៅចំពោះមុខរបស់ពួកគេនោះ។ ព្រះជាម្ចាស់នៅតែឈរទតមើល។ ប៉ុន្តែពួកគេនៅតែ ជឿជាក់ថាទ្រង់ជាព្រះពិត។ ពួកគេបានធ្វើការឆ្លើយសារភាព។ ព្រះបានជ្រាបគ្រប់យ៉ាង ពីការដែលពួកគេបានធ្វើ។ ពួកគេជឿជាក់ថាទ្រង់គឺជាព្រះពិត។

55 ដូច្នេះពួកគេបានដើរ តម្រង់គុកភ្លើងនោះ។ នៅចុងក្រោយនេះខណៈពេលនោះព្រះបានយាងមកពីលើមេឃ មកនៅលើរទេះខ្យល់ ខ្យល់បក់ចេញដល់ពួកគេខណៈ ដែលទ្រង់កំសាន្តពួកគេ ហើយមានបន្ទូលទៅកាន់ពួកគេ។

56 ព្រះអនុញ្ញាតសេចក្ដីជំនឿរបស់អ្នកមកដល់កន្លែងនេះដែលជាជំនឿដ៏រឹងមាំ។

57 នៅគម្ពីរសញ្ញាចាស់ យ៉ូប នៅពេលដែលសាតាំង ដែលជាអ្នកចាំចោទប្រកាន់គាត់ បានចោទប្រកាន់គាត់ ថាជាមនុស្សមានបាប។ ប៉ុន្តែលោកយ៉ូប បានដឹងថាគាត់ មិនមានអំពើបាបនោះទេ។ លោកបានដឹងថាអ្វីដែលលោកបានធ្វើ តែងតែខុសនឹងបំណងព្រះហរទ័យរបស់ព្រះ ហើយបានសារភាព គ្រប់យ៉ាងដែលលោកធ្វើហើយបានថ្វាយតង្វាយ ដុតនៅទីនោះសម្រាប់ព្រះដែរ។ នោះគឺជាបំណងព្រះហរទ័យ របស់ព្រះ។ នោះហើយអ្វីទាំងអស់ដែលព្រះបានតម្រូវ គឺជាតង្វាយ ដុតទាំងមូលនិងសារភាពកំហុសរបស់លោកចំពោះព្រះ។ ហើយយ៉ូបក៏បានសម្រេចការងារទាំងនោះ។

58 ហើយសាតាំងបាននិយាយថា "ខ្ញុំនឹងយកអូដ្ឋរបស់គាត់ ដ្បិតគាត់ជាអ្នកមាន ខ្ញុំ នឹង យកចៀមរបស់គាត់។" ហើយទី បំផុតវាក៏ទាញយកកូនរបស់គាត់ ដែលជាសំណព្វចិត្តរបស់គាត់។

59 ស្មៀម យ៉ូបក៏នៅតែឈរ ដោយគាត់ដឹងថាព្រះគឺជាព្រះដ៏ពិត លោក បាន និយាយ ទៅកាន់ទ្រង់ហើយគាត់បានបំពេញតម្រូវការរបស់ទ្រង់។ គាត់បាន ស្វែងរកឃើញថា "ខ្ញុំបានធ្វើតង្វាយដុតទាំងមូលគ្រប់ពេល។ ខ្ញុំ បាននិយាយ នៅក្នុងចិត្តរបស់ខ្ញុំថា 'ប្រហែលជានៅពេលកូនប្រុសរបស់ខ្ញុំធ្វើបុណ្យម្តង—ម្តងហើយកូនស្រីរបស់ខ្ញុំដែលចូលរួម ប្រហែលជា ពួកគេបាន ប្រព្រឹត្ត អំពើ បាប សម្ងាត់ នៅក្នុងចិត្តរបស់ពួកគេដូច្នេះខ្ញុំនឹងថ្វាយជាតង្វាយ ដុតទាំងមូលដើម្បីលោះបាបពួកគេនិងការសារភាពកំហុស របស់ពួកគេដល់ព្រះ។'"

60 ឱព្រះជាម្ចាស់! នៅពេលដែលមនុស្សម្នាក់បានរក្សាអ្វីដែលព្រះបានធ្វើ គាត់ប្រាកដថាព្រះគឺជាព្រះដ៏ពិតទ្រង់ត្រូវតែឆ្លើយតប។ ជំនឿដាស់សតិរបស់គាត់ គ្រប់ពេលវេលា។

61 នៅពេលដែលអ្នកបានធ្វើនូវអ្វីដែលអ្នកដឹងថាត្រឹមត្រូវពេលអ្នកបំពេញតម្រូវការរបស់ព្រះ ពេលអ្នកសារភាពនិងធ្វើការកែតម្រូវហើយសងអ្វីៗទាំងអស់ដាក់នៅចំពោះ ព្រះ។ ខ្ញុំមិនខ្វល់ថាតើទ្រង់នៅស្ងៀមប៉ុណ្ណាទេ តែព្រះជាម្ចាស់នៅតែជាព្រះពិត ដដែលរងចាំដាក់សេចក្តី ជំនឿនៅចំពោះទ្រង់ ។ អ្នកបានសម្រេចការរបស់អ្នកហើយឥឡូវនេះទ្រង់ចង់ ឃើញ សេចក្តីជំនឿរបស់អ្នកដោយការប្រព្រឹត្តរបស់អ្នក។ ទ្រង់ចង់ឃើញ នូវអ្វីដែលអ្នកនឹងធ្វើ។

62 ប្រសិនបើអ្នកបានត្រូវរើសតាំងហើយបានអធិស្ឋានទៅព្រះ ទ្រង់កំពុងរងចាំមើល នូវអ្វីដែលអ្នកនឹងជឿ។ មិនបានទៅដល់ថ្ងៃអាទិត្យក្រោយ និងថ្ងៃ បន្ទាប់និងជាឱសថកាត់តាមទីក្រុង។ ទ្រង់រងចាំមើល ការប្រតិកម្ម និងជំនឿរបស់អ្នក។ មិនដើរត្រឡប់មកវិញ ថ្ងៃបន្ទាប់ហើយនិយាយថា "ខ្ញុំមាន អារម្មណ៍ថាមិនល្អទេ ខ្ញុំគិតថាខ្ញុំមិនបានប្រោសឱ្យជាទេ។" អ្នកបានអធិស្ឋានមិន សម ឬជាលើ កដំបូងនៅកន្លែងណា។ អ្នកមិនទាន់។ អ្នកមិនទាន់។ អ្នកមិនទាន់ មានជំនឿ នៅឡើយទេ។ អ្នកមិនជឿថាទ្រង់ជាព្រះទេ។ ខ្ញុំមិន...

63 អ្នកអាចនឹងនិយាយថា "បងប្រុសប្រានហាំ ខ្ញុំមិនយល់ស្របជាមួយនឹង អ្នកទេ។" សកម្មភាពរបស់អ្នកផ្ទាល់បានបង្ហាញឃើញនូវអ្វីដែលអ្នកមាន។ "តាមរយៈ

ផលផ្លែរបស់ពួកគេអ្នកនឹងស្គាល់ពួកគេ។” ប្រសិនបើមនុស្សម្នាក់ បាននិយាយថា គាត់គឺជាគ្រីស្ទានម្នាក់ ហើយគាត់នៅតែផឹក ជក់បារី លេងល្បែង និងការនិយាយ រឿងដែលអាសអាភាស "បើតាមព្រះគម្ពីរគឺជាផ្នែកមួយដែល បង្ហាញថាគាត់មិន មែនជាអ្នកជឿព្រះទេ” នៅតែជាមនុស្សមានបាប។ គាត់ជា មនុស្សដែលមិនត្រឹមត្រូវទេ។

64 ប៉ុន្តែ នៅពេលដែលអ្នកសារភាពដោយត្រង់ទៅព្រះ ទ្រង់ជាព្រះរបស់អ្នកដដែលជីវិតរបស់យើងគឺស្ថិតនៅក្នុងព្រះហស្តរបស់ទ្រង់សូមយើងបាន ប្រកាសថា "ទ្រង់ជាម្ចាស់នៃខ្ញុំ ខ្ញុំជាដីឥដ្ឋព្រះអង្គជាជាងស្មូន” បន្ទាប់មកអធិស្ឋានទូលសួរនូវ អ្វីដែលអ្នកនឹងត្រូវធ្វើ។ នោះសេចក្តីជំនឿនឹងមិនផ្លាស់ប្តូរឡើយ។ យើងនឹងឈរមាំនៅទីនោះជានិច្ច។

65 ទោះបីជាកាលៈទេសៈហាក់ដូចជាការធ្លាក់ចុះទៅស្តាំនិងឆ្វេង ប៉ុន្តែជំនឿ នោះមិនដែលផ្លាស់ប្តូរទេ ព្រោះដោយសារតែអ្នក មានជំនឿថាទ្រង់ជាព្រះពិត។ ហើយបើសិនជាទ្រង់ជាព្រះជាម្ចាស់ ទ្រង់នឹងរក្សាសេចក្តីសន្យារបស់ទ្រង់។ ទ្រង់នឹងសម្រេច ការសន្យារបស់ទ្រង់។ ទ្រង់មិនដែលបំភ្លេចសន្យារបស់ទ្រង់ទេ។ បើទ្រង់ជាព្រះទ្រង់នឹងរក្សាសេចក្តីសន្យារបស់ទ្រង់។ អូ ខ្ញុំស្រឡាញ់ ដូច្នោះ។ ទ្រង់គួរតែគង់នៅជាមួយយើង។

66 យ៉ូបថ្វាយតង្វាយរបស់លោក លោកបានធ្វើអ្វីៗគ្រប់យ៉ាង។ គាត់ដឹងថាគាត់ធ្វើត្រូវ។ ហើយនៅទីនេះ មានសមាជិកក្រុមជំនុំនឹងសមាជិកមួយ ចំនួនជានិកាយផ្សេងទៀត បាននិយាយថា "យ៉ូបបាន សារភាពថាលោក ជាមនុស្សមានបាបចំពោះព្រះទ្រង់នឹងមិនដាក់ទោសឱ្យលោកទេ លុះត្រាតែលោកជាមនុស្សបាប។”

67 ប៉ុន្តែយ៉ូបបាននិយាយថា "ខ្ញុំបានសារភាពបាបរបស់ខ្ញុំ។ ខ្ញុំបានថ្វាយ តង្វាយដុតទាំងមូលដល់ព្រះ ហើយខ្ញុំមិនមែនជា មនុស្សបាបទៀតទេ។” លោក បានដឹងថាលោកជាមនុស្សបែបណាហើយឥឡូវ។ បន្ទាប់មកអ្វីគ្រប់យ៉ាង នៅតែល្អទៅមុខ ទៅមុខ ទៅមុខ គ្រាន់តែជាការលំបាកពេលដែលយើងទៅ យ៉ូបព្យាយាមដើម្បីនឹងទៅកន្លែងមួយដែលលោកអាចទៅ នឹងបដិសេធមិនទទួលស្គាល់ ព្រះនិង តង្វាយដុតដល់ព្រះដែរ។ គ្រប់នាទីការអ្វី ដែលអ្នកសារភាព វាបានបង្ហាញពីភាព ទន់ខ្សោយនិងការសង្ស័យដល់ព្រះរបស់អ្នក។ អ្នកសូមព្រះសម្រាប់អ្វីទាំង

នោះ ហើយដើរដោយការសង្ស័យរបស់អ្នកបន្ទាប់មកអ្នកក្លាយ ជាអ្នកសង្ស័យម្នាក់ មិន មែនជាអ្នកជឿព្រះទេ។

68 យ៉ូបដឹងពីកន្លែងដែលលោកបានឈរ លោកបានឈរនៅលើគ្រឹះដ៏មាំនោះ។

69 គ្មានអ្វីឆ្ងល់ទេដែលលោក ផើរូនែត បាននិយាយ ពេលគាត់ហៀបនឹងស្លាប់

លើព្រះគ្រីស្ទថ្មដារឹងមាំខ្ញុំឈរ
គ្រប់ដីទាំងអស់ជាខ្សាច់ដែលលេចលង់។

70 នៅលើថ្មដារឹងមាំនៃ ការសារភាពរបស់យ៉ូប សូម្បីតែភរិយាជាទីស្រឡាញ់របស់គាត់ក៏ដើរចេញដែរ។ នៅពេលដែលសុខភាពរបស់លោក បានចុះ ខ្សោយទៅហើយបូសមានពេញរាងកាយរបស់គាត់ គាត់សំអាតខ្លួន ហើយបណ្តាសារថ្ងៃកំណើតរបស់គាត់។ គាត់និយាយ "សូមព្រះអាទិត្យកុំបញ្ចេញ ពន្លឺ! សូមអោយព្រះច័ន្ទមានពន្លឺព្រិចៗនៅពេលយប់។"

ប្រពន្ធរបស់គាត់និយាយថា "យ៉ូបអ្នកមាន ទុក្ខវេទនាណាស់។ ហេតុអ្វីបានជាអ្នកមិន ដាក់បណ្តាសារ ព្រះជាម្ចាស់របស់ អ្នកហើយស្លាប់ទៅ?"

71 គាត់និយាយថា "អ្នកនិយាយដូចជាស្ត្រីល្ងង់។" គាត់បានប្រាកដថាមានព្រះ ហើយលោកបានជួបទ្រង់។ អូ ខ្ញុំមានអារម្មណ៍ខ្ញុំជាអ្នកគោរពសាសនាម្នាក់។ គាត់បានដឹងថាគាត់បំពេញនូវតម្រូវការរបស់ព្រះ ហើយនោះជាដំណោះស្រាយ។ ព្រះបានសាកល្បងជំនឿរបស់គាត់។ ទ្រង់សាកល្បងអ្នក។ ទ្រង់សាកល្បងខ្ញុំ។

72 ប៉ុន្តែនៅពេលដែលយើងបំពេញតម្រូវការទ្រង់ "ចូរប្រែចិត្ត អ្នកទាំង អស់ គ្នា ហើយទទួលបុណ្យជ្រមុជទឹកក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ សម្រាប់ផ្តាច់ ពីអំពើបាបរបស់អ្នក ហើយអ្នកនឹងបានទទួលអំណោយទាន នៃព្រះវិញ្ញាណ បរិសុទ្ធ" ដែលជាការសន្យារបស់ទ្រង់។ "ក្នុងចំណោមអ្នករាល់គ្នាណាដែលមានជំងឺចូរហៅពួកចាស់ទុំនៃក្រុមជំនុំមក។ សូមពួកគេឱ្យចាក់ប្រេងតាំង ហើយអធិស្ឋានដល់ពួកគេ។ ពាក្យអធិស្ឋានដែលផុស ចេញពីជំនឿនឹងសង្គ្រោះ អ្នក ជំងឺ នោះ ហើយ ព្រះនឹង ព្យាបាលពួកគេ។" នោះគឺដោះស្រាយហើយ។ "សារភាពកំហុសរបស់អ្នកទៅវិញទៅមកទាំងអធិស្ឋាន អោយគ្នា ទៅវិញទៅមកដែរ។" អ្នកនឹងស្គាល់ ពីព្រះទ័យរបស់ព្រះ។

73 "ទីសម្គាល់ទាំងនេះត្រូវបានបង្ហាញតាមពួកគេដែលជឿ។ នៅក្នុងឈ្មោះអញ ពួកគេ នឹងអាចដេញអារក្ស ពួកគេនឹងអាចនិយាយចេញភាសារថ្មី ប្រសិនបើពួក គេ ចាប់ពស់ ឬផឹកអ្វីដែលស្លាប់នោះវានឹងមិនប៉ះពាល់ដល់ ពួកគេ ឡើយ ប្រសិនបើពួកគេដាក់ដៃរបស់ពួកគេនៅលើកន្លែងដែលឈឺនោះពួកគេនឹងបានជាឡើងវិញ។"នោះដោះស្រាយហើយ។

74 ចូរប្រាកដថាព្រះជាព្រះដ៏ពិត។ ត្រូវប្រាកដថានៅក្នុងចិត្តរបស់អ្នកជឿថានោះហើយជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។ យ៉ូបបានជឿដូច្នោះ។

ប្រពន្ធរបស់គាត់បាននិយាយថា "ហេតុអ្វីបានជាអ្នកមិនដាក់បណ្តាសារទ្រង់ហើយស្លាប់ទៅ? ហេតុអ្វីបានជាអ្នកទទួលបាន ការអាក្រក់គ្រប់ពេលវេលា។"

75 សាតាំងចូលចិត្តធ្វើរបៀបដូច្នេះដាក់អ្នកដែរ។ "ហេតុអ្វីបានជាអ្នកមិនរកការល្អ ប្រសើរជាង ពេលដែលអ្នកត្រូវបានរើសតាំង។ អ្នកមិនបានល្អប្រសើរជាងទេ ពួកគេបានអធិស្ឋានសម្រាប់អ្នកហើយ។ ពួកគេជាគ្រូគង្វាលមិនត្រឹមត្រូវ នៅក្នុងការអធិស្ឋានលើកដំបូង។" វាមិនសំខាន់លើគ្រូអធិប្បាយ។ វាសំខាន់គឺជំនឿដ៏រស់នៅក្នុងព្រះរបស់អ្នកជាមុន។ មិនមែនជាអ្វីដែលគ្រូអធិប្បាយនោះទេ តែវាជាអ្វីដែលព្រះបានមានបន្ទូល។ ការអធិប្បាយនេះមិនសំខាន់ដូចការសន្យា របស់ព្រះជាម្ចាស់បានសន្យានោះទេ។ មិនមែនអាស្រ័យលើគ្រូអធិប្បាយនោះទេគឺអាស្រ័យនៅលើព្រះនិងជំនឿរបស់អ្នកទេ តែចូរជឿថាព្រះគឺជាព្រះពិត។ ដូច្នេះត្រូវ ប្រាកដថាព្រះជាព្រះពិត។ ត្រូវប្រាកដថាទ្រង់ជាព្រះ ហើយនោះជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ហើយព្រះជាម្ចាស់គង់នៅក្នុង ព្រះបន្ទូលរបស់ទ្រង់។

76 ហើយយ៉ូបបាននិយាយថា"អ្នកនិយាយដូចជាស្ត្រីល្ងង់។" ហើយបាននិយាយ ថា "នេះព្រះជាម្ចាស់បានផ្តល់ ហើយព្រះជាម្ចាស់បាននាំយកទៅវិញ សូមលើក តម្កើង ព្រះនាមរបស់ព្រះអម្ចាស់។" លោកបាន ប្រាកដថាទ្រង់ជាព្រះ។

77 ហើយនៅពេល ដែលលោកបាននិយាយចេញពីមាត់របស់លោក ផ្គរលាន់ចាប់ផ្តើមគ្រហឹម ហើយផ្លេកបន្ទោរចាប់ផ្តើមបញ្ចេញពន្លឺ។ ព្រះជាម្ចាស់នៅតែបន្តមានផែនការសម្រាប់លោក។ លោកតែងតែស្រែកហៅទ្រង់ នៅគ្រប់ទីកន្លែង។ ទ្រង់នៅតែមិនទាន់ឆ្លើយតបជាមួយលោក។

78 នោះហើយជាអ្វីដែលគាត់កំពុងធ្វើ។ មើលជនជាតិអាមេរិចគឺ ដូចកំពុងស្ថិត នៅក្នុងឋាននរក ពួកគេមានពុត ហើយទៅព្រះវិហារតែថ្ងៃអាទិត្យតែប៉ុណ្ណោះ។ ខ្ញុំមិន ខឹង ទេ។ ប៉ុន្តែខ្ញុំស្អប់អំពើបាប គ្មាននរណាម្នាក់ត្រឹមត្រូវ ជាមួយព្រះទេ។ ទេ ខ្ញុំមិនខឹងជាមួយនឹងប្រទេសនេះ ហើយក៏មិនដែលខឹងនឹងប្រជាជនដែរ ប៉ុន្តែខ្ញុំខឹង នឹងអារក្សដែលបានបណ្តាលប្រជាជនជួបរឿងទាំងនេះ។

79 ពួកគ្រូគង្វាល និងគ្រូអធិ ប្បាយដែលខ្វាក់ភ្នែកទាំងនេះ បានអនុញ្ញាតអារក្ស ពង្វក់ពួកគេ ដោយទេវសាស្ត្រដែលមនុស្សបង្កើត។ អ្នកត្រូវតែកើតជាថ្មីម្តង ទៀត។ ហើយព្រះនឹងរក្សាព្រះបន្ទូលរបស់ទ្រង់។ សម្លឹងមើលទ្រង់ដូចដែលរក្សាពួកគេ។ ប្រសើរជាងនេះទៅទៀតត្រូវប្រាកដថាទ្រង់ គឺជាព្រះ ដែល គង់នៅទីនោះ។ "មាន ទម្រង់នៃការគោរពកោតខ្លាចព្រះបដិសេធនូវអំណាចទាំងនោះ។"

80 ពួកអ្នកក្រីក្រ និងស្ត្រីម្នាក់ នាងបានដឹងថាទ្រង់ជាព្រះ។ ម្សៅក្នុងធុង របស់នាងបានស្រកចុះៗៗៗ គ្រប់កាលៈទេសៈដែលនាងបានទទួល គឺកាន់តែ អាក្រក់ទៅៗគ្រប់ពេលវេលា។ ប៉ុន្តែព្រះទ្រង់បានអនុញ្ញាត ឲ្យអារក្សសាកល្បងនាង។ ទ្រង់សព្វព្រះព្រះទ័យនឹងការសាកល្បង។ ទ្រង់ស្រឡាញ់ការសាកល្បងជំនឿ របស់នាងដើម្បីដឹងពីរបៀប ដែលនាងនឹងប្រព្រឹត្តយ៉ាងណា។ នាងត្រូវ រើសតាំងហើយ នាងបានអធិស្ឋានតែបន្ទាប់មកធ្វើឲ្យនាងកាន់តែមានបញ្ហាអាក្រក់ ជាច្រើន កើតឡើង។ ទ្រង់បានមានបន្ទូលថា "សូមមកនេះសាតាំងហើយ ចូរសាកល្បង ដល់លោកចុះ។" អញដឹងថាគេជឿជាក់លើអញ។ ព្រះប្រទានពរជារៀងរហូត! អូ ប្រង ប្រុសប្រានហាំទះដៃរបស់គាត់ពីរដង—Ed។] "សូមសាកល្បងគេឥឡូវនេះ។ អញដឹងប្រាកដថាគេនឹងអធិស្ឋានដល់អញ។" តើគេនិយាយបែបនេះចំពោះអ្នក?

81 ទ្រង់មានបន្ទូលពីយ៉ូបដូច្នេះ។ ទ្រង់មានបន្ទូលថា "ធ្វើអ្វីដែលអ្នកចង់ធ្វើ ប៉ុន្តែ អ្នកមិនត្រូវយកជីវិតរបស់គេទេ ព្រោះអញដឹងថាគេស្រឡាញ់អញ។ គេបាន ថ្វាយតង្វាយដុតទាំងមូលដល់អញ។ គេបានធ្វើតាមបំណងអញ។ គេបានធ្វើអ្វី ដែល អញបានប្រាប់គេឱ្យធ្វើ ហើយគេជឿជាក់លើអញ។ ឥឡូវចូររមៀលគាត់ លើធ្យូង ប្រសិន បើអ្នក ចង់។" ទ្រង់បានដកអ្វីគ្រប់យ៉ាងពីលោក។ ព្រះបានឲ្យគាត់ ទ្វេ ដង នៅ ពេលដែលទ្រង់ផ្តល់ឲ្យគាត់។ ប្រាកដណាស់ទ្រង់ធ្វើបែបនោះ។

82 ទ្រង់បានដាក់ជំនឿរបស់យើង ដើម្បីធ្វើការសាកល្បង ចង់ដឹងថាយើងពិតជា ជឿថាទ្រង់ជាព្រះពិត។

83 ស្ត្រីនោះគ្មានការសង្ស័យទេ ហើយបាននិយាយថា "ខ្ញុំបានអធិស្ឋាន។ ខ្ញុំបានអធិស្ឋាន។ ខ្ញុំដឹងថាខ្ញុំជាសាសន៍ដ៏ទៃដែលមិនសក្តិសមនោះទេ។"

84 សូមចាំថាព្រះយេស៊ូវបានមានបន្ទូលអំពីនាងនៅក្នុងព្រះគម្ពីរនេះ។ ទ្រង់មានបន្ទូលថា "គ្មានស្ត្រីមេម៉ាយណាផ្សេងអាចបំរើអេលីយ៉ាទេឬអី? ប៉ុន្តែលោកត្រូវបានបញ្ជូនទៅជាមួយនាងដែលជាសាសន៍ដទៃ។"

85 "អូ" លោកបាននិយាយថា "ខ្ញុំបានអធិស្ឋាន។" ប្រហែលជា នៅពេលដែលនាងបានឃើញម៉ៀវជិតអស់ហើយការស្លាប់នឹងចូលមកដល់មាត់ទ្វារ។ មួយដុំតូច នាងនិងកូនប្រុសរបស់នាងនឹងស្លាប់។ អញអាច មើលឃើញ ការ អធិស្ឋានរបស់នាងរាល់យប់ ក្នុងខ្យល់ក្តៅនិងផែនដី ជិតនឹងឆេះទៅហើយ។ ហើយមនុស្សកំពុងយំស្រែក យំនៅតាមផ្លូវ ដោយសារ ការអត់ឃ្លាន។ នាងបានដើរទៅវិញទៅមកៗនៅផ្ទះរបស់នាង។ នាងបានសម្លឹង មើលកូនប្រុសតូចរបស់នាង។ មើលទៅកូន តូចរបស់នាងហើយសម្លៀកបំពាក់របស់ពួកគេទាំងអស់រហែក ហើយមានថ្មេរជា ច្រើន។ មើលទៅដៃរបស់នាង ឡើងជ្រីវជ្រួញ។ នាងដើរត្រឡប់ទៅវិញទៅមកហើយបាននិយាយថា "ខ្ញុំដឹងថាទ្រង់ជាព្រះ។ ខ្ញុំ បានសារភាព កំហុស ទាំងអស់ដល់ ទ្រង់។ ខ្ញុំបានធ្វើអ្វីគ្រប់យ៉ាងដែលទ្រង់សព្វព្រះទ័យ។ ខ្ញុំកំពុងសូមនូវជីវិតរបស់យើងថ្វាយសិរីរុងរឿងដល់ទ្រង់។" ព្រះបានឃើញពីអ្វីដែលនាងកំពុងធ្វើ។

86 ពួកគេឯទៀតបានចេញទៅរាំនៅកន្លែងណាមួយ តែងខ្លួនស្អាតៗ ឡើងកម្មវិធីទូរទស្សន៍មួយទំនើប ឬអ្វីមួយដែលជារបៀបរបស់លោកិយ។ ប៉ុន្តែ ស្ត្រីម្នាក់នោះគឺនៅតែម្នាក់ឯងជាមួយព្រះជាម្ចាស់។

87 ពេលព្រឹកមកដល់។ នាងបាននិយាយថា "កូនតូចរបស់នាងបានយំ ស្រែកឡើងរាល់យប់ដោយសារគ្មានម្សៅសម្រាប់បរិភោគ។ តើខ្ញុំនឹងធ្វើអ្វី ជាមួយ ម្សៅមួយក្តាប់នេះ?"

88 អ្នកដឹងហើយថាម្សៅគឺជាព្រះគ្រីស្ទ។ សិស្សព្រះគម្ពីរខ្លះស្គាល់ថាព្រះគ្រីស្ទគឺជា ម្សៅ–តង្វាយ។ រីឯម្សៅ–តង្វាយត្រូវតែកិនជាមួយឧបករណ៍ ពិសេស រហូតដល់វាក្លាយជាបំណែកតូចៗដូចជាពោត;ពីព្រោះព្រះយេស៊ូវគ្រីស្ទដូចកាលពី ម្សិលមិញ ថ្ងៃនេះ និងជារៀងរហូត។ គ្រប់អ្នកជឿទាំងអស់ជឿបែបនោះនិងសំរាក ដូចនោះ។ ហាលេលូយ៉ា! អ្នកអាចដើរតាមនិស្ស័យចាស់ និងប្រព័ន្ធគោលទ្ធិតាមតែងអ្នកចង់បាន។ សម្រាប់ខ្ញុំ ខ្ញុំជឿលើព្រះគ្រីស្ទគឺដូចកាលពី ម្សិលមិញ ថ្ងៃនេះ និង

ជារៀងរហូតព្រះជាម្ចាស់មិនផ្លាស់ប្រែទេ។ ខ្ញុំមានគោលជំហររបស់ខ្ញុំនៅក្នុងពិភព នៃសេចក្តីជំនឿរបស់ខ្ញុំ ខ្ញុំមានភាពស្មោះត្រង់របស់ខ្ញុំ។ ខ្ញុំនៅតែជឿថាទ្រង់ជាព្រះដដែល ពីម្សិលមិញ ថ្ងៃនេះ និងជារៀងរហូត។

89 ពួកគេកិនផ្តាច់បន្តិចម្តងៗដដែលៗ ពីព្រោះទ្រង់គឺនៅតែដដែល។ ទ្រង់នៅ តែជាព្រះដូចកាលពីមុន ទ្រង់គង់នៅទីនេះនៅព្រឹកនេះហើយនៅកន្លែងនេះ។ ទ្រង់នៅតែជាព្រះដដែល។ នោះជាអត្ថន័យម្សៅនោះ។

90 ហើយប្រេងមានន័យថាព្រះវិញ្ញាណដូចដែលយើងបានដឹងហើយ យោងតាមព្រះគម្ពីរអេសេគាល ជំពូក៤ជាដើម។ នោះជាមូលហេតុដែលយើងបានចាក់ប្រេងតាំងជាមួយនឹងប្រេងជាព្រះវិញ្ញាណ។ តើវាគឺជាអ្វី? ក្នុងគម្ពីរយ៉ូហានជំពូក៤ "ព្រះវរ បិតាសព្វព្រះហឫទ័យនឹង អ្នកថ្វាយបង្គំដោយវិញ្ញាណនិង សេចក្តីពិតណាស់។" ព្រះយេស៊ូវជាសេចក្តីពិត។ ទ្រង់ជា ម្សៅ–តង្វាយ និងប្រេងនេះជា ព្រះវិញ្ញាណ។ ហើយព្រះវិញ្ញាណបញ្ចូលជាមួយ សេចក្តីពិតនឹងនាំមកនូវអ្វីមួយ។ ដាក់វារួមគ្នាវាធ្វើបានជានំមួយ។ អូ!

91 តើជំនឿរបស់អ្នកនៅឯណា? នៅពេលដែលព្រះបន្ទូលរបស់ព្រះ បានអធិប្បាយដោយភាពសមញ្ញតែនៅក្នុងអំណាចរបស់វានោះ ព្រះយេស៊ូវគ្រីស្ទគឺជាព្រះដដែល ម្សិលមិញ ថ្ងៃនេះ និងជារៀងរហូត ហើយព្រះបន្ទូលគឺជា ម្សៅ ហើយអ្នក មានប្រេងដើម្បីលាយជាមួយគ្នា។ វាប្រហែលជាមួយក្តាប់ដៃឬមួយ ស្លាបព្រា ប៉ុន្តែយ៉ាងណាក៏ដោយវាជាការពិត។

92 ឥឡូវនេះតើវាត្រៀមចាំអ្វី? ជាការត្រៀមខ្លួនជាស្រេចសំរាប់ឈើឆ្កាង។ ការត្រៀមខ្លួនជាស្រេច សម្រាប់ការលះបង់ខ្លួនឯង។ នោះហើយជាអ្វីដែល អ្នកត្រូវធ្វើ។ ប្រសិនបើព្រះបន្ទូលត្រូវបានអធិប្បាយ ហើយអ្នកមាន ព្រះវិញ្ញាណហើយ វាក៏ លាយ ចូលគ្នា វាជាការលះបង់ខ្លួនឯងដើម្បីបដិសេធរាល់ការឈឺចាប់ ដើម្បីបដិសេធរាល់ជំងឺគ្រប់យ៉ាង ដើម្បីបដិសេធរាល់ការប្រឆាំងផ្ទុយពីព្រះបន្ទូលរបស់ព្រះ ហើយឈររឹងមាំលើវា។

93 គ្រូពេទ្យបាននិយាយថា*នេះ នោះ ឬផ្សេងទៀត* កុំធ្វើឲ្យមានការខុសគ្នា។ អ្នកឈរលើវាពីព្រោះព្រះមានបន្ទូលដូច្នេះ។ ម្សៅមក មកដល់។ អ្នកមាន ប្រេង។ អ្នកបានលាយវា ជាមួយគ្នា។

94 ឥឡូវនេះខ្ញុំឮសំឡេងមួយ។ វាឮតិចបន្ទាប់ពីពន្លឺថ្ងៃបានរះ។ មានសំឡេងមួយនិយាយថា "ចូរចេញទៅសំយាបផ្ទះ អ្នកនិងរើសបានកំណាត់ ឈើពីរ កំណាត់។" តើអ្នកសម្គាល់ឃើញថាមានបទគម្ពីរនិយាយថា "កំណាត់ ឈើពីរ?" ឈើឆ្កាង។ នាងមានម្សៅនិងប្រេងប៉ុន្តែនាងត្រូវបានហៅដើម្បីធ្វើ ធ្វើជា មួយវា។ អ្នកមិនធ្លាប់ទទួ លបានម្សៅនិងប្រេងដូចដែលអ្នកចង់បាន ប៉ុន្តែអ្នកត្រូវតែធ្វើ ការ លះ បង់ខ្លួនឯង។

95 កំណាត់ឈើពីរ។ កាលពីបុរាណពួកគេមិនដែលរកបានវិធីល្អប្រសើរ សម្រាប់បង្កើតភ្លើងឡើយ។ នៅពេលដែលអ្នកយកឈើមួយកំណាត់ និងដាក់វា នៅពាក់កណ្តាលដើម្បីដុតវា។ ប្រជាជនឥណ្ឌា បានដុតភ្លើងរបស់ពួកគេ។ ខ្ញុំបានដុតវាច្រើនដងរាល់យប់។ គ្រាន់តែយកកំណាត់ឈើមួយ ហើយតាមរបៀប*នេះ* ហើយមួយរបៀប*នោះ* និងនៅតែបន្តរុញវាចុះឡើងនឹងបង្កើតបានជាភ្លើងឆេះ។

96 ឈើនោះគឺជាឈើឆ្កាង។ "កំណាត់ឈើពីរ" ព្រះគម្ពីរបានចែង។ មានសំឡេងបាននិយាយថា "ចូរចេញទៅសំយាបផ្ទះអ្នក ហើយរើសយកឈើពីរ កំណាត់។" ដូចគ្នានេះដែរនៅលើភ្នំ មានសំឡេងមួយលាន់លឺចុះទៅដល់ ហោរា ម្នាក់ថា "ចូរទៅទីក្រុង។ ទ្រង់បានបង្គាប់។" អូខ្ញុំអើយ! ពួកគេទាំងពីរបាន ស្តាប់តាម។ ពេលខ្លះត្រូវតែកើតឡើង។ ពួកគេទាំងពីរនាក់ស្តាប់តាមបង្គាប់។

97 ប្រសិនបើគ្រូអធិប្បាយបានអធិប្បាយពី ព្រះបន្ទូលហើយអ្នកដែលទទួលវាហើយជឿ និងធ្វើវា នឹងមានអ្វីមួយត្រូវតែកើតឡើង។ ប្រសិនបើអ្នកជាមនុស្សមានបាបអ្នកត្រូវតែបានសង្គ្រោះ។ ប្រសិនបើអ្នកឈឺអ្នកត្រូវបានព្យាបាលព្រោះព្រះបានសន្យាហើយ ប្រសិនបើយើងពិត ប្រាកដជា មួយព្រះ។

98 ពិតប្រាកដណាស់ទ្រង់ជាព្រះ ទ្រង់ត្រូវតែរក្សាព្រះបន្ទូលទ្រង់។ ប្រាកដ! បន្ទាប់មក បញ្ជាគឺ "ចូរទៅទីក្រុង ដ្បិតអញបានបង្គាប់ ស្ត្រីមេម៉ាយម្នាក់។" និម្មិតមួយបានកើតឡើងនៅចំពោះហោរានោះ។ គាត់កំពុងដើរ។ គាត់មិនដឹងថាគាត់ទៅកន្លែងណាទេ វាមិនមានអ្វីខុសគ្នាទេ។ គាត់គ្រាន់តែស្តាប់ តាមបង្គាប់របស់ព្រះ។

99 នាងមិនដឹងថាកំណាត់ឈើពីរនោះនៅកន្លែងណាទេប៉ុន្តែមានកំណាត់ ឈើពីរនៅក្នុងទីធ្លាផ្ទះរបស់នាង។ នាងបានចាប់ផ្តើមគិត។ នាងចេញទៅ ទីធ្លាផ្ទះ។ នាងស្លឹងមើលជុំវិញខ្លួន "អូ! ពិតមែន!" ពេលនោះមានសំឡេងស្រែកពីទីក្រុងយប់នេះនឹងមានចោរនៅទីនោះ អ្នកផឹកស្រានឹងស្រវឹង ដើរប្រវេប្រវារនៅ តាមបណ្តោយ

ផ្លូវជាដើម។ នាងសម្លឹងមើលទៅផ្លូវ។ នាងគ្មានឃើញ អ្វីទាំងអស់។ នាងបានរក ឃើញឈើតែមួយកំណាត់មួយផ្នែកនៃឈើឆ្កាង ការលះបង់ខ្លួនឯង។ នាងទទួលបាន មួយកំណាត់ឈើផ្សេងទៀត។ ហើយពេលដែលនាងរើសកំណាត់ឈើទីពី…

100 អូពេលនោះវាស្រអាប់ពេលសេចក្ដីស្លាប់នឹងមកដល់មាត់ទ្វារ។ នាងនិង កូនប្រុសរបស់នាងនឹងបរិភោគនំមួយដុំតូចហើយនឹងស្លាប់ទៅ។ នោះជាអ្វីទាំងអស់។ ហើយពេលខ្លះនៅ កណ្ដាលភាពស្រអាប់យើងអាចឮសំឡេងនោះ។

101 នៅពេលដែលនាង បានរើសកំណាត់ឈើទីពីរ ហើយរៀបត្រលប់មកវិញ សំលេងមួយបានមកដល់ទ្វារ ហើយនិយាយថា "ចូរយកទឹកមក ខ្ញុំផឹកបន្តិច"។

102 នាងបានងាកមើលដោយទាំងមានកំណាត់ឈើ ទាំងពីរនៅក្នុងដៃរបស់នាងជាមួយនឹងម្សៅនិងប្រេងលាយបញ្ចូលគ្នាជាស្រេច។ នាងបាននិយាយថានាងបានធ្វើការលាយវាជាមួយគ្នារួចបាត់ហើយ។ នោះហើយជាព្រះបន្ទូល និង ព្រះវិញ្ញាណត្រូវលាយជាមួយគ្នា។ ដាក់នៅលើឈើឆ្កាងលះបង់ខ្លួនឯង បដិសេធ នូវអ្វីដែលផ្ទុយពីអ្វីដែលអ្នកធ្លាប់សួរ។ នោះត្រូវហើយ។ "ខ្ញុំបានលាយបញ្ចូល គ្នាឥឡូវខ្ញុំទៅយក កំណាត់ឈើទាំងពីនោះសិន។"

សំលេងនោះ បាននិយាយថា "ចូរយកទឹកមកខ្ញុំផឹក បន្តិច។"

103 នាងមើល ហើយនាងឃើញបុរសម្នាក់ឈរច្រត់នៅច្រកទ្វារ ថ្ពាល់ក្រហមមានពុកចង្កា ក្បាលទំពែក មានអាយុចំណាស់ ហើយមានស្បែកចៀម រុំនៅ ជុំវិញលោក។ មើលទៅលោកជាប្រភេទ សុភាពបុរសចំណាស់ម្នាក់។

104 នាងនិយាយ "ខ្ញុំនឹងចែករំលែកទឹករបស់ខ្ញុំជាមួយនឹងគាត់។" ទឹកនៃជីវិតអ្នកព្រមឲ្យវាទៅនរណាម្នាក់ ប្រាប់នរណាម្នាក់ ឲ្យទៅកន្លែងណាមួយ។ "ចាំ បន្តិចលោក។" នាងត្រឡប់មកជាមួយកំណាត់ឈើពីរនៅដៃរបស់នាង។

105 ហើយសំឡេងបានលាន់លឺម្ដងទៀតថា "មិនត្រឹមតែចែកទឹកឲ្យខ្ញុំទេ ប៉ុន្តែសូមចែកនំប៉័ងនៅក្នុងដៃរបស់អ្នកបន្តិចផង។" នំប៉័ងនៃជីវិត។ ទឹកនៃ ជីវិត! តើវាជាជីវិត? នាងនឹងឆាប់ស្លាប់ដូចនឹងការវិនាស។ "ចូរយកទឹករបស់អ្នកមកឲ្យខ្ញុំ យកនំប៉័ងរបស់អ្នកមកឱ្យខ្ញុំ។"

106 តើយើងរកអ្វីនៅទីនេះ? តើអ្វីដែលយើងអាចរៀនពីមេរៀននេះ? "ចូរស្វែងរកនគរ និងសេចក្តីសុចរិតរបស់ព្រះជាមុនសិន ទើបរបស់ទាំងអស់បានប្រទានដល់អ្នករាល់គ្នា។"

"ចូរយកទឹកនិងចំនីនៃនំប៉័ងមួយមកឲ្យខ្ញុំ។"

107 បន្ទាប់មកនាងបានងាកទៅរកភាពស្រអាប់។ អញបានស្តាប់ឮនាង និយាយ "លោកម្ចាស់អើយ!" គឺបែបនេះ "ខុសគ្នាពីមនុស្សដ៏ទៃដែលខ្ញុំបានឃើញ និងមនុស្ស ដែលខ្ញុំបានលឺពីមុន។ អ្នកហាក់ដូចជានិយាយអ្វីដែលជាការល្អ។ ប៉ុន្តែ ខ្ញុំមានត្រឹមតែ ម្សៅមួយក្តាប់និងប្រេងមួយស្លាបព្រាតែប៉ុនោះ។ ខ្ញុំបានលាយវា រៀបនឹងចំអិនវាហើយជាមួយកំណាត់ឈើទាំងពីរនេះ។ ហើយខ្ញុំនឹងកូនប្រុសរបស់ ខ្ញុំបរិភោគវាហើយនឹងស្លាប់ទៅ។ នោះហើយជាអ្វីដែលខ្ញុំមាន។"

108 បន្ទាប់មកអ្វីដែលយើងនឹងឮបន្ទាប់? "ប៉ុន្តែយកនំ១ដុំតូចឱ្យខ្ញុំជាមុនសិន។" យកព្រះជាទីមួយ។ មិនខ្វល់ថាអ្នកណានិយាយយ៉ាងណា អ្វីផ្សេងណា ភស្តុតាងអ្វី វាស្រអាប់ប៉ុណា វាទៅជាយ៉ាងណានោះទេ ចូរយក ព្រះជាទីមួយ។ ព្រះបន្ទូលព្រះជាមុន។

109 "វេជ្ជបណ្ឌិតបាននិយាយ ខ្ញុំមិនអាចជានោះទេ។" ប៉ុន្តែយកព្រះបន្ទូល ព្រះជាទីមួយ។ ខ្ញុំពិតជាមនុស្សមានបាបច្រើនពេកហើយ។ ខ្ញុំជាស្រីពេស្យា។ ខ្ញុំជាអ្នកលេងល្បែងស៊ីសង។ ខ្ញុំជាមនុស្សប្រមឹក។

ព្រះបន្ទូលរបស់ព្រះជាទីមួយ។ "ទោះបើអំពើបាបរបស់គេច្រើនយ៉ាងណា ពួកគេនឹងក្លាយទៅជាសដូចហិមៈបាបក្រហមឆ្អិនឆ្អៅក្តីគង់តែពួកគេនឹងក្លាយ ជាសដូចជារោមចៀម។" ទីមួយគឺព្រះ។

110 "ទៅហើយយកនំមួយដុំតូចឲ្យខ្ញុំជាមុនសិន ។ ទាំងអស់ដែលអ្នកមានយកវាមកឲ្យខ្ញុំ។" តើយល់ព្រមឲ្យវាទៅក្នុងព្រះហស្តរបស់ព្រះទេ?

111 ជីវិតរបស់ខ្ញុំទាំងអស់ដែលខ្ញុំមាន។ ខ្ញុំមានអាយុហាសិបឆ្នាំ។ "តើអ្នកព្រមទេលោកវីលៀមប្រានហាំដាក់ជីវិតរបស់អ្នកមកអញ? តើអ្នកស្ម័គ្រចិត្តទេក្មេងតូចៗក្នុង ការ ដាក់ជីវិតរបស់អ្នកមកអញ? តើអ្នក ស្ម័គ្រចិត្តទេ? តើអ្នកអាចធ្វើវាបានទេអ្នកមានជំងឺ? តើអ្នកទុកចិត្តអញទេ? ចូរដាក់អញជាទីមួយក្នុងជីវិតរបស់ឯង។"

112 "ចូរយកនំប៉័ងមួយដុំដែលនៅក្នុងដៃរបស់អ្នក ហើយយកទឹកមកបន្តិចផង។" នាងបានសម្លឹងមើលគាត់។ មានអ្វីមួយបានប្រាប់នាងថាបុរសម្នាក់ដឹងច្បាស់ពី អ្វីដែលគាត់កំពុងនិយាយ។

ព្រះស្គាល់ចៀមរបស់ទ្រង់។ "ចៀមរបស់អញស្គាល់សំឡេងរបស់អញ។ ពួកគេដឹងថាជាបទគម្ពីរ ឬមិនមែន ថាតើវាជាការត្រឹមត្រូវឬអត់។"

113 នាងងាកមកស្តាប់បង្គាប់។ នោះហើយជាអ្វីដែលអ្នកត្រូវធ្វើ។ ហើយនៅពេលដែលនាងងាកមកស្តាប់តាមអ្វីដែលហោរាបាននិយាយបន្ទាប់មកក៏មានផ្គរលាន់ពីឋានសួគ៌ដែលពួកគេបានឮគ្រប់គ្នា។ ដ្បិតមានផ្គរលាន់ ចេញពីសំឡេងរបស់ហោរា ថា ដែលមនុស្សមានបាបនិងអ្នកមានជំងឺប្រាថ្នាចង់ឮ "**ព្រះបន្ទូលរបស់ព្រះជាម្ចាស់**។"

114 តើយើងចង់ឮវាដូចម្តេច! តើមនុស្សទាំងនោះដើតាមផ្លូវរបស់ខ្ញុំហើយ និយាយថា "ចូរមកឯទ្វារនេះ។ កូនស្រីរបស់ខ្ញុំគឺមកតាម *នោះដែរ*។កូនរបស់ខ្ញុំបានបន្ទាបខ្លួន ដូច្នេះ។ គ្រាន់តែធ្វើតាមព្រះបន្ទូលរបស់ ព្រះជាម្ចាស់។" តើអ្នកអាចនិយាយយ៉ាង ម៉េចមុនពេលព្រះបន្ទូលបានដល់ក្នុងមាត់របស់អ្នក? អ្នកចង់និយាយដោយខ្លួនឯង។ ប៉ុន្តែពួកគេបានឮពី "**ព្រះបន្ទូលរបស់ព្រះជាម្ចាស់**។"

115 វាបានមកឆ្លងកាត់របងព្រោះនាងស្តាប់បង្គាប់។ ភាពស្រអាប់បានរលាយបាត់ទៅ។ "**ព្រះបន្ទូល របស់ព្រះជាម្ចាស់**។ ធុងម្សៅនេះ នឹងមិន នៅទទេ ឬដប ប្រេងនឹងមិនត្រូវរីងស្ងួតទេ រហូតដល់ថ្ងៃដែលព្រះអម្ចាស់ជាព្រះ បានបង្អុរភ្លៀង ធ្លាក់លើផែនដីនេះវិញ។" អូ ជាអ្វីដែលការលួងលោមចិត្ត!

116 នាងបានធ្វើនំ។ នាងបានឲ្យនំនោះ ទៅហោរាពិសារ។ ហើយនាងបានត្រឡប់ មកវិញនឹង បានធ្វើនំមួយចំនួន សម្រាប់កូនប្រុស និងខ្លួននាងផ្ទាល់។ ហើយ ពួកគេបានបរិភោគ និងបានផឹកបានជាច្រើនថ្ងៃនៅលើផែនដីនេះ។

117 តើវាបានកើតមកពីណា? តើវាទទួលបានដោយរបៀបណា? វិទ្យាសាស្ត្រប្រាប់ខ្ញុំនូវម្សៅនោះបានមកពីណា។ ហើយប្រេងបាន មកពីណា? ដូចម្តេច បានជាវាមាននៅក្នុងដបនោះ? នាងបានឃើញវាស្ងួត ជារៀងរាល់ព្រឹក។ នាងបានធ្វើឲ្យធុងម្សៅទទេជារៀងរាល់ព្រឹក ហើយនៅស្ងួត។ ប៉ុន្តែនៅពេល ដែល នាង បាន

ត្រឡប់មកមើលវិញវាមានកាន់តែច្រើននៅទីនោះ។ តើវាបានមកពី ណា? វាបាន មកដោយសារព្រះបន្ទូលរបស់ព្រះ។ ប្រាកដជាព្រះ។ ទ្រង់ជាអ្នកបង្កើត។

118 អ្នកប្រហែលជាបានបាត់បង់សុខភាពរបស់អ្នក។ អ្នកប្រហែលជា បាត់បង់ ការប្រកបគ្នា។ ចូរយកទ្រង់ តាមព្រះបន្ទូលទ្រង់ចុះ។ ប្រាកដថាទ្រង់ជាព្រះ។ ភាព ស្រអាប់ ដែលអ្នកឃើញឥឡូវវាមិនស្រអាប់ទៀតទេ បើគ្រាន់តែទទួលយក ព្រះបន្ទូលទ្រង់និងប្រាកដថាទ្រង់គឺជាព្រះ។

119 នៅក្នុងប្រទេសអាល្លឺម៉ង់ ខ្ញុំបានឃើញរូបភាពមួយ វាតែងតែជាប់ក្នុងចិត្ត ខ្ញុំ។ វិចិត្រករបានលាបរូបភាពនោះ...ដែលហៅថា—ថា "ទឹកដីពពក។" ហើយ នៅពេល ដែលអ្នកឃើញវាពីចម្ងាយ វាជារូបភាពដ៏អាក្រក់ វាមានសភាពស្រអាប់ ដែលអ្នក មិនធ្លាប់ឃើញពីមុនមក។ វាគ្រាន់តែជាដុំពពកនៅរួមគ្នា ពេលដែលអ្នក បានសម្លឹងមើលវាពីចម្ងាយ។ ប៉ុន្តែនៅពេលដែលអ្នកបានមើលវាកាន់តែជិត វានឹង ផ្លាស់ប្តូរ។ នោះជាស្លាបពួកទេវតា នៃព្រះមករួមគ្នាច្រៀង ហាលេលូយ៉ាថ្វាយដល់ ព្រះជា ម្ចាស់។ ដូច្នេះបានជាស្រអាប់នៅពេលខ្លះ។ ប្រសិនបើអ្នកសម្លឹងមើលទៅ វាពី ចម្ងាយវាមើលទៅអាប់អួរនិងងងឹតដូចយប់។ ប៉ុន្តែស្តាប់តាមព្រះ ហើយ ព្រះ បន្ទូល របស់ទ្រង់ និងប្រាកដថា ទ្រង់ជាព្រះ ហើយជិតស្និទ្ធទៅព្រះវបិតា អ្នកនឹង រកឃើញ វាគ្រាន់តែជាការមករបស់ពួកទេវតានៃព្រះ។

120 នាងក៏ដូចជាលោកអ័ប្រាហាំដែរ នាងបានអំពាវនាវដល់ព្រះ ដើម្បីផ្តល់នូវអ្វី គ្រប់យ៉ាងដែលនាង ថ្វាយយញ្ញបូជានៅលើអាសនៈ។ ប្រហែលជាអ្នក ត្រូវបាន ហៅដូចនាងដែរនៅព្រឹកនេះ។ លះបង់ផ្លូវរបស់អ្នក។ លះបង់ការមិនជឿរបស់អ្នក។ លះបង់អ្វីគ្រប់យ៉ាងដែលអ្នកមាន។ បន្ទាប់មក យកប្រេងនិងព្រះបន្ទូលនេះលាយ ជាមួយគ្នា ហើយដាក់នៅលើអាសនៈយញ្ញបូជា។ អ្នកនឹងឃើញព្រះគ្រប់ទីកន្លែង ដូចដែលខ្ញុំកំពុងឈរលើវេទិកានេះ។

ចូរគិតអំពីការនោះខណៈដែលយើងអធិស្ឋាន។

121 តើអ្នកមានតម្រូវការទេថ្ងៃនេះ? តើអ្នកចង់មានអ្នកដែលអស្ចារ្យជាង អាចជួយ សាច់ ឈាមអ្នកបានទេ? តើលុយរបស់អ្នកតិចពេកមិនអាចបង់ថ្លៃជួលបាន? តើ កូនរបស់អ្នកត្រូវការស្បែកជើងថ្មី ហើយអ្នកមិន មាន លុយទិញឲ្យពួកគេបានទេ? តើធុងនៅក្នុងផ្ទះរបស់អ្នកទទេ ហើយដបក៏ស្ងួត ទៀត? អ្នកមិនអាចទិញម្សៅផ្ទុក ក្នុងស្តុកបាន? នៅទីនោះមានអ្វីមួយខុស? ចូរចាំថាទ្រង់បានសន្យាហើយ។

122 តើអ្នកមានជំងឺហើយគ្រូពេទ្យប្រាប់ថាអ្នកត្រូវការវះកាត់? អ្នកមិនមានប្រាក់ដើម្បីធ្វើវាទេ? អ្នកមានតម្រូវការ។

123 តើអ្នកជាមនុស្សបាបឬ? បើអ្នកត្រូវការរបស់មួយយ៉ាងខ្លាំង ដឹងថា បើព្រះគួរហៅថ្ងៃនេះអ្នកនឹងបាត់បង់? តើអ្នកជាអ្នកដែលបែរចេញពីព្រះ ចង់រត់គេចពីព្រះ? ហើយអ្នកដឹងថា អ្នកជាកម្មសិទ្ធរបស់ព្រះវិហារមួយប៉ុន្តែអ្នកដឹងថា អ្នក មិនត្រឹមត្រូវ ទេ? មនសិការរបស់អ្នកប្រាប់អ្នក យោងតាម ព្រះបន្ទូល អ្នកមិនត្រឹមត្រូវទេ។ ហើយ អ្នកមានតម្រូវការ។ សូមកុំឱ្យព្រះបន្ទូលនេះធ្លាក់ចុះទៅក្នុងដីបន្លា ឬនៅលើដីថ្មក្នុងចិត្តអ្នកឡើយ។ សូមឱ្យធ្លាក់ចុះទៅក្នុងដីល្អ ហើយមានជីជាតិវិញ។

124 ប្រសិនបើអ្នកឈឺហើយអ្នក...លោកគ្រូពេទ្យនិយាយថាអ្នកមិនអាចជា សះស្បើយ ដូច ដើមទេ ហើយអ្នកបានសន្យានឹងព្រះថា អ្នកនឹងបម្រើទ្រង់អស់ មួយជីវិត របស់ អ្នក បើអ្នកបានជឿថា ព្រះគឺជាព្រះដ៏ពិត ហើយនឹងធ្វើតាមព្រះទ័យរបស់ទ្រង់។ ប្រសិនបើអ្នកត្រូវការអ្វីមួយជាដំបូងអ្នកត្រូវអធិស្ឋានដល់ ព្រះដើម្បីដែអ្នកបានធ្វើការជាច្រើនសម្រាប់បំរើព្រះសូមព្រះប្រទានពរដល់អ្នក។

សូមយើងអធិស្ឋានទាំងអស់គ្នា។

125 ឱព្រះអម្ចាស់អើយនេះគ្រាន់តែជាការមួយចំនួននៅក្នុងវេទិកានៅព្រឹកនេះ កូនដឹងថាគ្មានដៃណាមួយលើកឡើងនោះទេបើគ្មានទ្រង់ ទ្រង់ដឹងគ្រប់ការទាំង អស់ដែលកូន កំពុងធ្វើសម្រាប់ទ្រង់។ ទ្រង់មានបន្ទូល "តើគេមិនលក់សត្វចាបជាច្រើនថ្លៃ១សេនទេឬអី? តើអ្នកមិនមានតំលៃ្លជាងចាបទេឬអី!" តើច្រើនយ៉ាង ណា ដែលទ្រង់ឃើញរូបកាយដែលរមែងស្លាប់នេះ ដែលព្រះបុត្រារបស់ទ្រង់ព្រះយេស៊ូវ គ្រីស្ទបានសុគតសំរាប់! តើច្រើនប៉ុណ្ណាដែលទ្រង់ឃើញតំលៃពួកគេលើសជាងសត្វចាបទៅ ទៀត ប្រសិនបើវាបានធ្លាក់ចុះ នៅព្រឹកនេះ! ខ្ញុំគិតថាសម្រាប់...ចាបរាប់សិបក្បាលនឹងលក់មិនបានមួយកាក់ទេព្រឹកនេះពីព្រោះគ្មាននរណាចង់បានពួកគេទេ។ ហើយនឹងមានបញ្ហាក្នុងការកប់ពួកគេ។ ប៉ុន្តែទ្រង់ស្គាល់ពួកគេ ម្នាក់ៗទ្រង់ដឹងពីផ្នែកនៃ រាងកាយរបស់ពួកគេ។ ទ្រង់ ដឹងគ្រប់ទាំងសក់នៅលើ ក្បាល របស់ យើងម្នាក់ៗ។

126 ឱព្រះអម្ចាស់អើយសូម ឆ្លើយការអធិស្ឋានរបស់កូនផង។ សូមឲ្យពួកគេដឹងប្រាកដនៅព្រឹកនេះថាទ្រង់ជាព្រះ ហើយវាជាព្រះវិញ្ញាណរបស់ទ្រង់។ សូមព្រះដកអស់ភាពរំភើបស្រើបស្រាលនិងការត្រាប់តាមសាសនាសម័យទំនើបចេញពីពួក

គេ "អូ! ខ្ញុំជាកម្មសិទ្ធិរបស់ក្រុមជំនុំបែប*នោះ*ពិតប្រាកដ។" ព្រះជាម្ចាស់ចូរដកគំនិតរបស់ពួកគេឥឡូវនេះ។ នៅក្នុងពេលនេះពួកគេអាចឃើញ ជីវិតដ៏អស់កល្បមួយ។ ហើយបន្ទាប់មកពួកគេនឹងស្វែងរកនិងស្រេកឃ្លាននូវការនេះ ដើម្បីឲ្យដឹងថាព្រះជាអ្វី ហើយពួកគេប្រាកដថាព្រះជាម្ចាស់ជាព្រះដ៏ពិត។ ទ្រង់បានរក្សាព្រះបន្ទូលរបស់ទ្រង់។

127 ដើម្បីមនុស្សមានបាប អាចកែប្រែចិត្តគំនិតបានយ៉ាងលឿន និងបានត្រៀមខ្លួនជាស្រេច សម្រាប់ការទទួលបុណ្យ ជ្រមុជទឹកក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ ហើយទ្រង់បានសន្យាថានឹងផ្ដល់ពួកគេនូវព្រះវិញ្ញាណបរិសុទ្ធដល់ពួកគេ។ ទ្រង់មានបន្ទូលដូច្នេះព្រះអង្គអើយ។ ទ្រង់នឹងរក្សាសេចក្ដីសន្យាទ្រង់។

128 មានអ្នកខ្លះងាកចេញ ហើយប្រាកដថាទ្រង់ជាព្រះ តែគេបានដើរ ចេញឆ្ងាយពីទ្រង់ទៅ។ សូមឲ្យពួកគេមកវិញថ្ងៃនេះព្រះអង្គអើយដោយសារទ្រង់មាន បន្ទូលថា "ទោះបីជាបានឯងក្រហមឆ្អិនឆ្អៅយ៉ាងណាក៏នឹងបានសដូចហិមៈ។ ក្រហមដូចជាមាសនឹងសដូចជារោមចៀម។"

129 ហើយប្រសិនបើមានអ្នកមានជំងឺសូមឲ្យពួកគេទទួលស្គាល់ថាទ្រង់ជាព្រះ។ ទ្រង់បានរក្សាទុកពាក្យសន្យារបស់ទ្រង់។ ទ្រង់ត្រូវតែរក្សា ពាក្យសន្យា របស់ទ្រង់។ ដូចដែលពួកគេបានថ្វាយជីវិតរបស់គេជាមួយនឹងប្រេង នៃព្រះ វិញ្ញាណ ដែលគង់នៅ ក្នុងពួកគេដែលជាអ្នកជឿ។ ហើយបន្ទាប់មកដោយមាន ព្រះបន្ទូលដែលជានំប៉័ង នៃជីវិតដែលជាការយោងទៅព្រះគ្រីស្ទនៃជីវិតរបស់ទ្រង់ជាដើម ពួកគេមា នឈ្មោះនៅក្នុងគម្ពីរសញ្ញាចាស់ហើយនៅក្នុងគម្ពីរសញ្ញាថ្មីដែរ ដើម្បីបង្ហាញថា ទ្រង់នៅតែជាព្រះដដែលម្សិលមិញ ថ្ងៃនេះ និងជារៀងរហូតទៅ។ សូមអោយ ពួកគេបាន លាយនូវព្រះបន្ទូលជាមួយនឹងប្រេងនៃព្រះវិញ្ញាណ ដែលពួកគេមាន ហើយក្រោកឈរនៅឯអាសនាទាំងពោលថា "នេះគឺជាអ្វីដែលខ្ញុំមាន។ ទូលបង្គំ នាំវាមក ។"

អូតើទ្រង់នឹងចម្រើនឡើងយ៉ាងណា! តើវាហៅថាព្រះនៃប្រវត្តិសាស្ត្ររបៀបណាតាមការដឹងដោយវិញ្ញាណ! តើនឹងត្រូវលើកព្រះយេហូវ៉ាយ៉ាងណា ចេញពីដួងចិត្តឡើងថា "យើងមានកូនដែលស្ដាប់បង្គាប់យើង។ អញបានដាក់គេឲ្យ សាកល្បង ហើយគាត់បានបង្ហាញថាគាត់ស្រឡាញ់អញនិងជឿលើអញ។ អញជាព្រះដ៏ ជាព្រះ។" ត្បិតបទគម្ពីរចែងថា "អ្នកណាដែលមកឯព្រះត្រូវជឿថាទ្រង់គឺជាព្រះ

ព្រះនឹងប្រទានរង្វាន់ដល់អ្នកដែលស្វែងរកទ្រង់។" សូមទទួល នៅម៉ោងនេះដូច ដែលយើងដាក់វាទៅកាន់ទ្រង់។

130 ហើយឥឡូវនេះខណៈពេលយើងនៅឱនចុះនៅឡើយ។ ហើយអស់អ្នកមាន តម្រូវការអ្វីផ្សេងៗ សូមឲ្យក្រោកឈរឡើង ដាក់វា...ឥឡូវបើអ្នកមិនទាន់ប្រាកដថា ទ្រង់គឺជាព្រះ...បើសិនអ្នកប្រាកដថាទ្រង់ជាព្រះហើយទ្រង់ នឹងរក្សានូវការសន្យា របស់ទ្រង់ សេចក្តីសង្គ្រោះ ការប្រោសឲ្យជា ឬអ្វីក៏ផ្សេងទៀត បើអ្នកប្រាកដថាទ្រង់ ជាព្រះសូមក្រោកឈរ។ បើអ្នកចង់អធិស្ឋានឲ្យអ្នកផ្សេងទៀតចូរក្រោកឈរឡើង។ បើសិន—បើសិនអ្នកប្រាកដថាទ្រង់ជាព្រះសូមដាក់ការទូលសូមនៅក្នុងក្រុមជំនុំ បរិសុទ្ធ។ អ្នកកំពុងធ្វើវាដូចដែល អ្នកកំពុងឈរ...[Ed—។]

"ខ្ញុំប្រាកដថាទ្រង់ជាព្រះ។ ខ្ញុំ ជឿថាទ្រង់រក្សាព្រះបន្ទូលរបស់ទ្រង់។ ខ្ញុំប្រាកដ ថាការទូលសូមរបស់ខ្ញុំ...ខ្ញុំនឹងថ្វាយនៅក្រោមឈាមឥឡូវនេះ។" ប្រសិនបើ អ្នក ថ្វាយ អំពើបាបទាំងអស់។ អំពើទាំងអស់ ជាការមិនជឿដល់ទ្រង់។ អ្នកអាចជា សមាជិកក្រុមជំនុំប៉ុន្តែខ្ញុំមានន័យថាអ្នកបាបនៃ"ការមិនជឿ"។ អ្នកបានថ្វាយវាជា គ្រឿងបូជា។ អ្នកនឹងថ្វាយយញ្ញបូជានោះ។ អ្នកកំពុងចូលមកដល់ឈើឆ្កាង។ អ្នក នឹង ថ្វាយយញ្ញបូជានិងថ្វាយទាំងការមិនជឿ របស់អ្នកដែរឥឡូវនេះ។ ហើយ ឲ្យវា ទៅកាន់ទ្រង់ហើយជឿថាទ្រង់ គឺជាព្រះអ្នកប្រាកដថា ទ្រង់នឹងឆ្លើយតប។ ប្រសិន បើអ្នក មានការទាំងនេះសូមលើកដៃ។ រក្សារបៀបដដែល។

131 ព្រះអម្ចាស់ទ្រង់ជាព្រះ។ នេះគឺជាប្រេងនិងពោតរបស់ពួកគេបាន លាយ បញ្ចូល គ្នា។ ពួកគេកំពុងតែនាំយកវាទៅឯឈើឆ្កាង ជាកន្លែង ដែលភ្លើងនៃ ព្រះ ជាម្ចាស់នឹងធ្លាក់ចុះមកក្នុងចិត្តរបស់ពួកគេ (ប្រសិនបើពួកគេពិតជា មានន័យបែប នោះ) ហើយសូមដុតនៅយញ្ញបូជានោះ។ អ្នកនឹងធ្វើចលនាលើកទឹកដែលលាក់កំ បាំង។ យាងមកពីស្ថានសួគ៌នៅក្នុងរទេះចំបាំងភ្លើង។ ទ្រង់នឹងអង្រួនផ្ទៃមេឃ និង ផែនដីដើម្បី ផ្តល់រង្វាន់ដល់ពួកគេ។

132 ដូចដែលពួកគេឈរជាមួយនឹងដៃលើកឡើងបញ្ជាក់ថាពួកគេបានជឿ និង ដាក់ ខ្លួន គេ ផ្ទាល់ និងការទូលសូមនៅលើអាសនៈរបស់ទ្រង់។ ឱព្រះវបិតានៃ ស្ថានសួគ៌ និងផែនដីប្រាកដជាការជំនុំជំរះស្ថានសួគ៌ និងផែនដីនឹងផ្តល់នូវសេចក្តី សុចរិត។ ប្រាកដថាទ្រង់នឹងរក្សាព្រះបន្ទូលរបស់ទ្រង់ ទ្រង់បានជ្រាបពីចិត្តមនុស្ស ប្រុស និងចិត្តមនុស្សស្រីនិងចិត្តរបស់មនុស្សទាំងនេះច្បាស់។

133 ព្រះអម្ចាស់ដ៏ជាព្រះទូលបង្គំសូមលើកដៃឡើង ដ្បិតខ្ញុំដឹងថាខ្ញុំនឹ ងទទួល ការផ្លាស់ប្តូរព័ន្ធកិច្ចឥឡូវនេះទៅ។ ហើយខ្ញុំជឿថាទ្រង់គឺជាព្រះ។ ខ្ញុំបានឃើញទ្រង់ឈរត្រង់ បង្គោលភ្លើង។ [បងប្រុសប្រានហាំគោះតុវេទិការបីដង—Ed។] ខ្ញុំបានឃើញទ្រង់ស្វែងរកចិត្តលាក់កំបាំងរបស់មនុស្ស។ ទ្រង់មិនដែលដួលម្តងឡើយ។ ទ្រង់បានសន្យានៅពេលដែលទ្រង់បានធ្វើវានៅកន្លែងផ្លូវនេះ នៅពេលដែលទ្រង់ចាប់ផ្តើមធ្វើការទាំងនេះ។ ហើយទ្រង់ការពារខ្ញុំនៅជុំវិញពិភពលោក ម្តងហើយ ម្តងទៀត។ ខ្ញុំប្រាកដថាទ្រង់គឺជាព្រះ។ ខ្ញុំប្រាកដដូច្នោះ។

134 ខ្ញុំបានថ្វាយខ្លួនឯងជាមួយមនុស្សទាំងនេះ និង យញ្ញបូជាទាំងអស់ដែល ខ្ញុំមានព្រះអង្គអើយដល់ទ្រង់សម្រាប់ជាយញ្ញនេះ។ ខ្ញុំនឹងចាប់ផ្តើមម្តងទៀតព្រះ អង្គអើយសូមធ្វើចលនាជុំវិញលោកីយ៍។ សូមជួយទូលបង្គំឱព្រះអង្គអើយ។ ប្រសិ នបើទូលបង្គំមានចិត្តមិនជឿពេលណាមួយសូមអត់ទោសបាបអោយខ្ញុំផង។ សូមអត់ទោសសម្រាប់ការ ដែលខ្ញុំភ្លេចពីជំនឿរបស់ខ្ញុំ។ ខ្ញុំដឹងថាទ្រង់គឺជាព្រះ ហើយទ្រង់នឹងប្រទានរង្វាន់ដល់អស់អ្នកដែល ស្វែងរកទ្រង់។

135 ដូចគ្នានេះដែរទូលបង្គំសូមសារភាពអំពើបាប របស់ប្រជាជនរបស់យើង នៅព្រឹកនេះ ភាពកំសោយរបស់ពួកគេ និងការសង្ស័យរបស់ពួកគេខណៈដែល ពួកគេកំពុងឈរជាមួយនឹងដៃលើកឡើង។ ទូលបង្គំសូមសារភាព អំពើបាបរបស់ពួកគេព្រះអង្គអើយនិងភាពកំសោយរបស់យើង។ សូមបញ្ជូន ព្រះវិញ្ញាណ បរិសុទ្ធមកលើ យើង ជាមួយនឹងត្រានៃការយល់ព្រមថាទ្រង់ គឺជាព្រះ។ ហើយទ្រង់ កំពុង តែមានវត្តមាននៅទីនេះនៅពេលនេះ ដើម្បីទទួល យើង ហើយនាំយើង ចូលទៅក្នុងព្រះហស្តរបស់ទ្រង់ និងដើម្បីលោះយើងពីអ្វី គ្រប់យ៉ាងដែលយើង បានបាត់បង់។ ប្រសិនបើសុខភាពយើងទ្រង់ស្តារឡើងវិញបានស្អាតមួយរយភាគរយ។ ប្រសិនបើព្រលឹងរបស់យើងសូមទ្រង់ប្រទានឲ្យរីកដុះដាលឡើង ភ្លឺចែងចាំងឡើង ពេញដោយព្រះវិញ្ញានបរិ សុទ្ធដើម្បីមានវត្តមាននៅចំពោះព្រះ។ ប្រសិនបើ ជាចិត្តមិនជឿ សូមទ្រង់យាងមកហើយម្តងទៀត ព្រះអង្គអើយ ជាសេចក្តីជំនឿ ដែលអាចរើភ្នំបាន។ សូមទទួលព្រះអង្គអើយ។

136 យើងជឿថាទ្រង់ធ្វើចលនា ព្រះវិញ្ញាណបរិសុទ្ធកំពុងធ្វើការក្នុងអាគារនេះ លើមនុស្ស ទាំងអស់នេះនិងក្នុងដួងចិត្តរបស់ពួកគេ អង្រួនពួកគេឲ្យ ទទួលយកព្រះដ៏រស់។ យើងធ្វើការនេះនៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។

ជំនឿខ្ញុំ មើលទៅទ្រង់
ជាចៀមនៃកាល់វ៉ារី
អង្គសង្គ្រោះ
ឥឡូវទ្រង់ឮ ពេលខ្ញុំអធិស្ឋាន
សូមដកយកបាបខ្ញុំចេញ
ហើយកុំឱ្យខ្ញុំវង្វេង
ចេញពីទ្រង់ឡើយ។

137 តើអ្នកមានន័យបែបនេះទេ? តើអ្នកទទួលបានទេ? ចូរលើកដៃឡើងនិយាយ
ថា "ឥឡូវនេះខ្ញុំទទួលបានហើយ។ ខ្ញុំជឿហើយ។"

ពេលជីវិតងងឹតសង្កត់ខ្ញុំ
មានទុក្ខព្រួយនៅជុំវិញ
ទ្រង់ធ្វើជាអ្នកនាំផ្លូវ
ដេញងងឹតទៅជាពន្លឺថ្ងៃនេះ
កំចាត់ទុក្ខព្រួយឱ្យឆ្ងាយ
កុំឱ្យខ្ញុំវង្វេង
ចេញពីទ្រង់ឡើយ។

ចូរយើងអោនក្បាលរបស់យើង។

138 បន្ទាប់ពីសារដ៏តឹងតែងទំលុះចិត្ត ធ្ងន់ៗ ហើយនាំអ្នកចេញពីផ្លូវដែលពិបាក
ប៉ុន្តែ វាជាការពិត។ ហើយប្រសិនបើអ្នកបន្ទាបខ្លួនជឿ ពីអ្វីដែលអ្នកបានសូមថា
ទទួល បាន កុំអនុញ្ញាតឲ្យបញ្ហារុញអ្នកចេញ ពីផ្លូលត្រង់នេះឡើយ។ ឈរមាំទី
នោះ។ មិនថាខ្ញុំអធិប្បាយច្រើនប៉ុណ្ណា ខ្ញុំធ្វើអ្វី ឬនរណាម្នាក់ធ្វើអ្វីនោះទេ វានឹងមិន
បានទទួលរហូតដល់អ្នកទទួលវាដោយខ្លួនអ្នកផ្ទាល់។

139 ប្រសិនបើអ្នកជឿដោយអស់ពីចិត្ត គ្រប់យ៉ាងដែលអ្នកប្រាថ្នា បើអ្នកបាន
សារភាពអំពើបាបរបស់អ្នក ព្រះនឹងអត់ទោសបាបដល់អ្នករាល់គ្នាដែរ។ កុំឲ្យមាន
ការសង្ស័យទៀតឡើយ។ ប្រសិនបើអ្នកជាអ្នកបែរចេញ អ្នកត្រូវបានត្រឡប់មកវិញ
នៅព្រឹកនេះ។ ប្រសិនបើអ្នកត្រូវការ ព្រះវិញ្ញាណបរិសុទ្ធអ្នកត្រូវទទួល បុណ្យជ្រ
មុជទឹកក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទដើម្បីលោះបាបរបស់អ្នក។ នោះហើយជាព្រះ
បន្ទូលរបស់ព្រះ។ ទ្រង់មិនមែនជាអាសនៈសំរាប់ព្រះវិហារ និកាយ ឬសំរាប់នរណា

ម្នាក់ផ្សេងទៀតនោះទេ។ ទ្រង់ត្រូវតែធ្វើតាមវិធីនោះ។ យើងត្រូវតែធ្វើតាមព្រះ ទ័យរបស់ព្រះមិនមែនតាមចិត្តរបស់ព្រះវិហារឡើយ។ នោះហើយជាអ្វីដែលយើង ត្រូវតែធ្វើ។

140 ទ្រង់មានបន្ទូលថា "ការអធិស្ឋាននៃសេចក្តីជំនឿ នឹងសង្គ្រោះអ្នកដែលឈឺ។" ប្រសិនបើអ្នកឈឺខ្ញុំអធិស្ឋានដោយសេចក្តីជំនឿសម្រាប់អ្នក។ អ្នកអធិស្ឋាន នៅក្នុងចិត្តរបស់អ្នក។ ហើយជឿជាក់ ទទួលយក ឈររឹងមាំលើផ្លូវនោះ។ វាត្រូវតែបែបនោះ។ គ្មានអ្វីអាចដកវា ចេញបានទេទោះបីជា វាស្រអាប់យ៉ាងណាក៏ដោយ។

141 ទ្រង់មានបន្ទូលថា "ល្អវាមើលទៅដូចជាខ្ញុំនៅតែមានជំងឺ។" នោះមិនថ្វីទេ... វាគ្រាន់តែជាស្លាបរបស់ពួកទេវតាប្រមូលផ្តុំគ្នាប៉ុនោះ។ វាតែប៉ុណ្ណឹង។ ជាព្រះជាទម្រង់នៃព្រះពរ។ វាមើលទៅអាប់អួរដល់អ្នក។ ត្រូវខិតទៅជិតបន្តិចហើយមើលទៅវាម្តងទៀត ឃើញ ប្រសិនបើយើងមិនទាន់ប្រាកដថាទ្រង់ គឺជាព្រះ ហើយទ្រង់ និងរក្សាព្រះបន្ទូលរបស់ទ្រង់។

142 ឥឡូវនេះដូចដែលយើងបានអានក្បាលចុះហើយខ្ញុំនឹងប្រគល់កម្មវិធី នេះទៅបងប្រុស នីវីលដែលជាគ្រូគង្វាលរបស់យើងវិញ។

**ចូរប្រាកដចិត្តអំពីព្រះ** KHM59-0125

(Be Certain Of God)

សារដែលធ្វើឡើងដោយ William Marrion Branham នេះ ត្រូវបានចែកចាយនៅព្រឹក ថ្ងៃអាទិត្យ ថ្ងៃទី ២៥ មករា ១៩៥៩ នៅ Branham Tabernacle in Jeffersonville, Indiana, U.S.A។ រាល់ការខិតខំត្រូវបានធ្វើឡើងដោយការផ្ទៀងផ្ទាត់យ៉ាងត្រឹមត្រូវ ជាសារសម្លេងចេញពីខ្សែអាត់ថត ចម្លង និងបោះពុម្ពដោយរក្សាសិទ្ធពីភាសាអង់គ្លេស។ ការបក ប្រែជាភាសាខ្មែរនេះ គឺត្រូវបោះពុម្ព និង ចែកចាយដោយ វ៉យ អូហ្វ ហ្គដ់ រីខដ ឌីង។

KHMER

©2018 VGR, ALL RIGHTS RESERVED

VOICE OF GOD RECORDINGS
P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.
www.branham.org

## ការរក្សាសិទ្ធ

សៀវភៅនេះត្រូវបានរក្សាសិទ្ធ។ សៀវភៅនេះអាចថតចម្លង បានជាការប្រើប្រាស់ផ្ទាល់ខ្លួន ដោយសេរី ឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូគ្រិស្ត។ សៀវភៅនេះ មិនអាចលក់ ផលិតជាទ្រង់ទ្រាយធំ យកទៅដាក់ក្នុងវែបសាយ លក់តាមប្រព័ន្ធអេលេចត្រូនិក ឬ បកប្រែ ដោយគ្មានការអនុញ្ញាតិពី វ៉យ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS®.)ឡើយ។

សម្រាប់ទំនាក់ទំនងបន្ថែម និង ឬសម្រាប់តម្រូវការទាក់ទងនឹងឯកសារសូមទំនាក់ទំនង៖

វ៉យស៍ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS)

P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.

WWW.BRANHAM.ORG